ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# លិខិតបទដ្ឋានគតិយុត្តិសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ច

| ល.រ | លេខលិខិត | ថ្ងៃខែលិខិត | របស់ | កម្មវត្ថុ |
|---|---|---|---|---|
| ១ | ១៤៦ អនក្រ.បក | ២៧-ធ្នូ-២០០៥ | រាជរដ្ឋាភិបាលកម្ពុជា | អនុក្រឹត្យ ស្តីពី សម្បទានដីសេដ្ឋកិច្ច |
| ២ | ៦៩ អនក្រ.បក | ២៨-មេសា-២០១៦ | រាជរដ្ឋាភិបាលកម្ពុជា | អនុក្រឹត្យ ស្តីពី ការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន |
| ៣ | ៩០ សសរ | ២៦-វិច្ឆិកា-២០១៨ | រាជរដ្ឋាភិបាលកម្ពុជា | សេចក្តីសម្រេច ស្តីពី ការតែងតាំងសមាសភាព នៃលេខាធិការដ្ឋានបច្ចេកទេស សម្រាប់សម្បទានដីសេដ្ឋកិច្ច |
| ៤ | ១១៣០ សជណ | ០១-តុលា-២០១២ | ទីស្តីការគណៈរដ្ឋមន្ត្រី | ករណីកែសម្រួលការកំណត់ថ្លៃសម្បទានដី និងបង់ប្រាក់កក់ចំពោះសម្បទានដីសេដ្ឋកិច្ចទាំងអស់ (ទាំងចាស់ ទាំងថ្មី) |
| ៥ | ៨១១ សជណ.ហធ | ១២-មិថុនា-២០១៩ | ទីស្តីការគណៈរដ្ឋមន្ត្រី | ករណីសំណើសុំគោលការណ៍លើការផ្ទេរធនធានចំណូលមិនមែនសារពើពន្ធពីចំណូលថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ |

| | | | | |
|---|---|---|---|---|
| ៦ | ១២៧៦ សហវ. ប្រក | ២៥-ធ្នូ-២០០៩ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រកាស ស្តីពី<br>ការកំណត់ថ្លៃស្នួយសារឈើឈរឡើងវិញ ដើម្បីបង់ចំណូលថវិការដ្ឋ |
| ៧ | ៧១៥/ ៥៨៥ ប្រក. សហវ. កសក | ២៣-កញ្ញា-២០១០ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រកាសរួម ស្តីពី<br>ការកែសម្រួលប្រការ២ នៃប្រកាសលេខ ១២៧៦ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ២០០៩ ស្តីពីការកំណត់ថ្លៃស្នួយសារឈើឈរឡើងវិញ ដើម្បីបង់ចំណូលថវិការដ្ឋ |
| ៨ | ៣៦៩ ប្រក.កសក | ២១-មិថុនា-២០១៦ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រកាស ស្តីពី<br>ការបង្កើតក្រុមជំនួយការលេខាធិការដ្ឋានបច្ចេកទេសសម្បទានដីសេដ្ឋកិច្ច |
| ៩ | ៦២១ ប្រក.កសក | ១៤-វិច្ឆិកា-២០១៧ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រកាស ស្តីពី<br>ការកែសម្រួលប្រធានក្រុមជំនួយការលេខាធិការដ្ឋានបច្ចេកទេស សម្រាប់សម្បទានដីសេដ្ឋកិច្ច |
| ១០ | ៥៩០៣/ ៣៨២ ក សក.នផ.ផក | ០៥-កញ្ញា-២០១៣ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សេចក្តីណែនាំលើការអនុវត្តនិងការផ្តល់របាយការណ៍ស្តីពី លទ្ធផលនៃការអនុវត្តគម្រោងវិនិយោគដីសម្បទានសេដ្ឋកិច្ច |
| ១១ | ៦៩១ សណន. កសក | ២៥-វិច្ឆិកា-២០១៦ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សេចក្តីណែនាំ ស្តីពី<br>វិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច |
| ១២ | ៧៥១៤ កសក | ២៣-សីហា-២០១៧ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សំណើរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ឱ្យបានរួចរាល់តាមនីតិវិធី |

| | | | | |
|---|---|---|---|---|
| ១៣ | ១០៧៧៣ កសក | ១១-ធ្នូ-២០១៧ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | លិខិតជូនដំណឹង ស្តីពី<br>ការជំរុញការអនុវត្តកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនរដ្ឋ |
| ១៤ | ២០០២ កសក | ២៨-កុម្ភៈ-២០១៩ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ស្តីពីការពង្រឹងការអនុវត្តគម្រោងសម្បទានដីសេដ្ឋកិច្ច |
| ១៥ | ១២០៩១ កសក | ២២-វិច្ឆិកា-២០១៩ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ស្តីពីការយកចិត្តទុកដាក់ពង្រឹងការចុះបញ្ជីដីរដ្ឋក្នុងដែនសមត្ថកិច្ច<br>របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត |
| ១៦ | ១៣៣០៤/១៩៣៥ កសក.គហ | ២៥-ធ្នូ-២០១៩ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ស្តីពីការកំណត់លើការគណនាថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ចត្រូវបង់ចូលថវិការដ្ឋ |

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ១៤៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## សម្បទានដីសេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦ ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លី ដែលមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីនីតិវិធី ការបង្កើតការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៥ ។

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ ._**

អនុក្រឹត្យនេះមានគោលដៅកំណត់លក្ខណៈវិនិច្ឆ័យ នីតិវិធី យន្តការ និងការរៀបចំស្ថាប័ន សម្រាប់ការផ្តួចផ្តើម និងការផ្តល់សម្បទានដីសេដ្ឋកិច្ច សម្រាប់ការតាមដានត្រួតពិនិត្យការអនុវត្តកិច្ចសន្យា និងសម្រាប់ការត្រួតពិនិត្យឡើងវិញលើសម្បទានដីសេដ្ឋកិច្ចដែលបានចុះកិច្ចសន្យាមុនពេលដែលអនុក្រឹត្យនេះចូលជាធរមាន ស្របតាមការកំណត់នៃច្បាប់ភូមិបាលឆ្នាំ ២០០១។

**មាត្រា ២ ._**

ពាក្យទាំងឡាយខាងក្រោមនេះ មានន័យដូចតទៅ÷

- សម្បទានដីសេដ្ឋកិច្ច សំដៅដល់យន្តការសម្រាប់ផ្តល់ដីឯកជនរបស់រដ្ឋ តាមរយៈកិច្ចសន្យាសម្បទានមួយជាក់លាក់ទៅឱ្យសម្បទានិក ដើម្បីប្រើប្រាស់សម្រាប់ធ្វើអាជីវកម្មកសិកម្ម និងកសិ-ឧស្សាហកម្ម
- ការធ្វើអាជីវកម្មកសិ-ឧស្សាហកម្ម សំដៅដល់
    - ការដាំដំណាំស្បៀង ឬ ដំណាំឧស្សាហកម្ម រាប់ទាំងការដាំដើមឈើជាចំការឈើ
    - ការចិញ្ចឹមសត្វ និងវារីវប្បកម្ម
    - ការងារសាងសង់ ដូចជារោងសិប្បកម្ម ឬរោងចក្រ និងការបំពាក់បរិក្ខារនានាសម្រាប់កែច្នៃ

វត្ថុធាតុដើម ដែលជាកសិផលក្នុងស្រុក ឬ

សកម្មភាពរួមគ្នានៃសកម្មភាពមួយចំនួន ឬទាំងអស់ដែលបានរៀបរាប់ខាងលើ

- អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា សំដៅដល់អាជ្ញាធរដែលមានសិទ្ធិអំណាចតាមផ្លូវច្បាប់ក្នុងការចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ដោយអនុវត្តសិទ្ធិនោះតាមការផ្តល់សិទ្ធិប្រទានពីនាយករដ្ឋមន្ត្រី និងបំពេញភារកិច្ចស្របតាមការចែងក្នុងអនុក្រឹត្យនេះ
- ស្ថាប័នដាក់បញ្ញត្តិ សំដៅដល់អាជ្ញាធរមានអំណាចតាមផ្លូវច្បាប់ក្នុងការចេញ និងដាក់ឱ្យអនុវត្តនូវវិធាន និងបទប្បញ្ញត្តិ ដើម្បីគ្រប់គ្រងលើសកម្មភាព ឬបរិក្ខារដែលជាកម្មវត្ថុនៃកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- លេខាធិការដ្ឋានបច្ចេកទេស សំដៅដល់លេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច ។

**មាត្រា ៣ .-**

សម្បទានដីសេដ្ឋកិច្ចអាចត្រូវបានផ្តល់ឱ្យ ដើម្បីសម្រេចគោលបំណងដូចខាងក្រោម ÷

- អភិវឌ្ឍសកម្មភាពកសិកម្មប្រពលវប្បកម្ម និងកសិ-ឧស្សាហកម្ម ដែលតម្រូវឱ្យមានការវិនិយោគដើមទុនដំបូងក្នុងអត្រាខ្ពស់ និងកម្រិតសមស្រប
- សម្រេចបាននូវការព្រមព្រៀងមួយចំនួនជាក់លាក់ពីអ្នកវិនិយោគ សម្រាប់ការអភិវឌ្ឍដីក្នុងលក្ខណៈសមស្រប និងប្រកបដោយចីរភាព ដោយផ្អែកលើផែនការប្រើប្រាស់ដីនៃតំបន់នោះ
- បង្កើតភាពមានការងារធ្វើនៅជនបទ ក្នុងក្របខ័ណ្ឌនៃការធ្វើប្រពលវប្បកម្ម និងការធ្វើឱ្យមានកាលានុវត្តភាពនៃការរកស៊ីចិញ្ចឹមជីវិតមានលក្ខណៈសម្បូរណ៍បែប និងក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងធនធានធម្មជាតិតាមប្រព័ន្ធអេកូឡូស៊ីសមស្រប
- លើកទឹកចិត្តរាល់ការវិនិយោគក្នុងគម្រោងសម្បទានដីសេដ្ឋកិច្ច និង
- បង្កើតចំណូលរដ្ឋ ឬចំណូលខេត្តក្រុង ឃុំសង្កាត់ តាមរយៈការប្រមូលថ្លៃប្រើប្រាស់ដី ពន្ធ និងកម្រៃលើសេវាពាក់ព័ន្ធ ។

## ជំពូកទី ២

## លក្ខខណ្ឌទៅសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច

**មាត្រា ៤ .-**

សម្បទានដីសេដ្ឋកិច្ច អាចត្រូវបានផ្តល់ឱ្យចំពោះតែដីដែលមានលក្ខណវិនិច្ឆ័យទាំង ៥ ដូចខាងក្រោម ÷

១. ដីដែលត្រូវបានចុះបញ្ជី និងធ្វើចំណាត់ថ្នាក់ ថាជាដីឯកជនរបស់រដ្ឋ ស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ និងអនុក្រឹត្យ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ។

២. ដីដែលមានផែនការប្រើប្រាស់ដី អនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ហើយការប្រើប្រាស់មានលក្ខណៈស្របទៅតាមផែនការនោះ ។

៣. ដីដែលបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមចំពោះការប្រើប្រាស់ និងការអភិវឌ្ឍដីសម្រាប់គម្រោងសម្បទាន។

៤. ដីដែលមានដំណោះស្រាយចំពោះបញ្ហាតាំងទីលំនៅថ្មីស្របតាមក្របខ័ណ្ឌគតិយុត្ត និងនីតិវិធីជាធរមាន។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវធានាថា មិនមានការបង្ខំឱ្យធ្វើការតាំងទីលំនៅថ្មីដោយគ្មានការស្ម័គ្រចិត្តពីអ្នកកាន់កាប់ដីស្របច្បាប់ និងត្រូវធានាចំពោះការគោរពសិទ្ធិមានច្រកចេញចូលទៅកាន់ដីឯកជន។

៥. ដីដែលមានការពិគ្រោះយោបល់ជាសាធារណៈអំពីគម្រោង ឬ សំណើសម្បទានដីសេដ្ឋកិច្ចជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលនៅក្នុងតំបន់។

**មាត្រា ៥ .-**

ការវាយតម្លៃសំណើសម្បទានដីសេដ្ឋកិច្ច ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ÷

- ការបង្កើនផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្ម ដោយប្រើប្រាស់បច្ចេកទេសទំនើប
- ការបង្កើតឱ្យមានការងារធ្វើកាន់តែច្រើន
- ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព
- ការចៀសវាង ឬការកាត់បន្ថយឱ្យនៅតិចបំផុតនូវហេតុប៉ះពាល់អវិជ្ជមានសង្គម
- ការផ្សារភ្ជាប់ និងការគាំទ្រទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច ប្រសិនបើមាន
- ការកែច្នៃវត្ថុធាតុដើម ជាកសិផលដែលត្រូវកំណត់នៅក្នុងកិច្ចសន្យាសម្បទាន។

## ជំពូកទី ៣
## នីតិវិធីសម្រាប់ផ្តួចផ្តើម ការស្នើសុំ និងការផ្តល់សម្បទានដីសេដ្ឋកិច្ច

**មាត្រា ៦ .-**

ការផ្តួចផ្តើមគម្រោងសម្បទានដីសេដ្ឋកិច្ច មានពីររូបភាពគឺ ÷

១. សំណើមានការអំពាវនាវ ដែលអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាជាអ្នកលើកគម្រោង ដើម្បីអំពាវនាវឱ្យអ្នកវិនិយោគដាក់សំណើ ។

២. សំណើមិនមានការអំពាវនាវ ដែលអ្នកវិនិយោគជាអ្នកលើកគម្រោងស្នើទៅរដ្ឋ ដើម្បីសុំការអនុញ្ញាត។

### ផ្នែកទី ១
### ការផ្តួចផ្តើមសម្បទានដីសេដ្ឋកិច្ចតាមរយៈការអំពាវនាវឱ្យដាក់សំណើ

**មាត្រា ៧ .-**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ជាអ្នកផ្តួចផ្តើមលើកគម្រោងសម្បទានដីសេដ្ឋកិច្ច តាមជំហានដូចតទៅ÷

១. រៀបចំឯកសារដំបូងសម្រាប់ស្នើគម្រោងសម្បទានដីសេដ្ឋកិច្ច តាមទម្រង់ដែលត្រូវបង្កើតឡើងដោយ

លេខាធិការដ្ឋានបច្ចេកទេស ហើយដែលត្រូវមានបញ្ចូលព័ត៌មានដូចចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យនេះ ។

២. បញ្ជូនឯកសារដំបូងទៅលេខាធិការដ្ឋានបច្ចេកទេស ដើម្បីធ្វើការពិនិត្យសិក្សា និងផ្តល់អនុសាសន៍បឋម ដោយផ្អែកលើមាត្រា ៧ និងមាត្រា ៩ នៃអនុក្រឹត្យនេះ ។

៣. ពិគ្រោះយោបល់ជាមួយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង និងជាមួយស្ថាប័នដាក់បញ្ញត្តិលើគម្រោងសម្បទានដីសេដ្ឋកិច្ច ។

៤. រៀបចំឱ្យមានការវាយតម្លៃដំបូងអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គមសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច ។

៥. ប្រសិនបើការវាយតម្លៃដំបូងអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម បង្ហាញនូវហេតុប៉ះពាល់អវិជ្ជមានកម្រិតមធ្យម ឬខ្ពស់ ត្រូវរៀបចំឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ។

៦. រៀបចំឯកសារពេញលេញសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ចដែលមានបញ្ចូលអនុសាសន៍ទាំងអស់ និងរបាយការណ៍នានាដែលជាលទ្ធផលនៃជំហានរៀបរាប់ខាងលើ ជាមូលដ្ឋានក្នុងការរៀបចំឯកសារ ស្តីពីលក្ខខណ្ឌសម្រាប់ការដាក់សំណើ ដែលមានការអំពាវនាវ ។

**មាត្រា ៨ ..**

ឯកសារដំបូងសម្រាប់ស្នើគម្រោងសម្បទានដីសេដ្ឋកិច្ច ត្រូវមានបញ្ចូលព័ត៌មានដូចខាងក្រោម ÷

១. ការពណ៌នាអំពីដីដែលស្នើឡើង ដូចជាទីតាំង ទំហំ ប្រភេទ លេខសម្គាល់ក្បាលដីដែលចុះក្នុងសៀវភៅគោលបញ្ជី ដីធ្លី និងព័ត៌មានទូទៅអំពីតំបន់ដែលដីនោះស្ថិតនៅ ។

២. ផែនការទូទៅអំពីការប្រើប្រាស់ និងការអភិវឌ្ឍន៍ដីសម្រាប់គម្រោងសម្បទាន ។

៣. សកម្មភាពចាំបាច់ផ្សេងៗដែលតម្រូវឱ្យសម្បទានិកធ្វើ មុនពេលចាប់ផ្តើមសកម្មភាពលើសម្បទានដីសេដ្ឋកិច្ចនោះ ប្រសិនបើមាន ។

៤. សកម្មភាពចាំបាច់ផ្សេងៗដែលតម្រូវឱ្យអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ឬក្រសួង ស្ថាប័នណាមួយធ្វើមុនពេលចាប់ផ្តើមអនុវត្តសកម្មភាពសម្បទានដីសេដ្ឋកិច្ច ប្រសិនបើមាន ។

៥. ការធានារបស់រដ្ឋ ឬកាតព្វកិច្ចរបស់រដ្ឋ ប្រសិនបើតម្រូវឱ្យមានសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច ។

**មាត្រា ៩ ..**

នៅពេលទទួលបានឯកសារពេញលេញសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច ពីអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំឯកសារ ដោយមានការអំពាវនាវឱ្យដាក់សំណើសុំសម្បទានដីសេដ្ឋកិច្ច រួមមាន ÷

- សេចក្តីជូនដំណឹង
- ឯកសារ ស្តីពីលក្ខខណ្ឌ និង
- ពាក្យស្នើសុំ ។

**មាត្រា ១០ ..**

លេខាធិការដ្ឋានបច្ចេកទេសត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ នូវសេចក្តីជូនដំណឹងឱ្យដាក់សំណើ និងបញ្ជូនសេចក្តីជូនដំណឹងនេះ ទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

សេចក្ដីជូនដំណឹងត្រូវបញ្ជាក់ពីរបៀប ទីកន្លែង និងរយៈពេលសម្រាប់ការដាក់សំណើ ដោយកំណត់នូវកាលបរិច្ឆេទទទួល និងឈប់ទទួលពាក្យ។ ការដាក់សំណើត្រូវមានរយៈពេលយ៉ាងតិច ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹង ។

## មាត្រា ១១ .-

ឯកសារ ស្ដីពីលក្ខខណ្ឌសម្រាប់ការដាក់សំណើដែលមានការអំពាវនាវ ត្រូវបញ្ចូលខ្លឹមសារដូចខាងក្រោម ÷

- សេចក្ដីពណ៌នា អំពីគម្រោងសម្បទានដីសេដ្ឋកិច្ច និងឯកសារគាំទ្រដែលតម្រូវឱ្យដាក់ភ្ជាប់ជាមួយសំណើ
- លក្ខណវិនិច្ឆ័យសម្រាប់ការវាយតម្លៃផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងពាណិជ្ជកម្មនៃសំណើ និង
- លក្ខខណ្ឌចាំបាច់មួយចំនួនដែលមិនអនុញ្ញាតឱ្យចរចា។

## មាត្រា ១២ .-

ពាក្យស្នើសុំសម្រាប់សំណើមានការអំពាវនាវ ត្រូវមានភ្ជាប់ព័ត៌មានទាំងឡាយដូចខាងក្រោម ÷

- ផែនការអាជីវកម្មដែលលំអិតអំពីផែនការប្រើប្រាស់ដី ផែនការវិនិយោគ ផែនការចំណូលចំណាយសម្រាប់ការអភិវឌ្ឍដី និងប្រភពដើមទុនសម្រាប់គាំទ្រដល់គម្រោងសម្បទាន
- ការពណ៌នា អំពីសេចក្ដីត្រូវការកម្លាំងពលកម្ម និងប្រភពផ្គត់ផ្គង់កម្លាំងពលកម្មសម្រាប់គម្រោងសម្បទាន
- ព័ត៌មានអំពីបច្ចេកវិទ្យា ឧបករណ៍ គ្រឿងចក្រ ជី ថ្នាំសម្លាប់សត្វល្អិត ប្រភេទដំណាំអាទិភាព ដែលគ្រោងនឹងប្រើប្រាស់
- ការបង្ហាញ ពីហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃសកម្មភាពគម្រោងវិនិយោគរបស់ខ្លួន ព្រមទាំងវិធានការទប់ស្កាត់ ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាន
- ការពណ៌នា អំពីការផ្សារភ្ជាប់ និងការគាំទ្រទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច ប្រសិនបើមាន
- ការពណ៌នា អំពីការផ្សារភ្ជាប់ទៅនឹងការកែច្នៃវត្ថុធាតុដើម ដែលជាកសិផលក្នុងស្រុក ប្រសិនបើមាន
- ថ្លៃប្រើប្រាស់ដីដែលអ្នកដាក់សំណើស្នើជូនរដ្ឋ
- ការបង្ហាញព័ត៌មានអំពីការកាន់កាប់ដីសម្បទានសេដ្ឋកិច្ចដោយម្ចាស់សំណើ ប្រសិនបើមាន ស្របតាមការចែងក្នុងមាត្រា ៥៩ នៃច្បាប់ភូមិបាល និង
- កិច្ចធានាណាមួយដែលអ្នកដាក់សំណើចង់បានពីរដ្ឋ ប្រសិនបើមាន។

## មាត្រា ១៣ .-

លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំការប្រជុំជាសាធារណៈ ដើម្បីបំភ្លឺអំពីចំណុចនានានៃឯកសារអំពាវនាវឱ្យដាក់សំណើ យ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទបិទការទទួលសំណើ និងត្រូវកត់ត្រាទុកជាឯកសារសាធារណៈនូវការបំភ្លឺដែលបានធ្វើឡើង ។

**មាត្រា ១៤ ..**

លក្ខណវិនិច្ឆ័យសម្រាប់វាយតម្លៃ និងចាត់ថ្នាក់សំណើមានការអំពាវនាវ ត្រូវបញ្ចូលចំណុចដូចខាងក្រោម÷

- កម្រិតបច្ចេកទេសនៃការប្រើប្រាស់ និងការអភិវឌ្ឍដី រួមទាំងភាពសមស្របរបស់ដី
- ការគោរពតាមស្តង់ដារបរិស្ថានជាតិ និងវិធានការសមស្របសម្រាប់ទប់ស្កាត់ ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គម
- លទ្ធភាពដំណើរការប្រតិបត្តិការនៃសំណើ ដោយផ្អែកជាអាទិ៍លើផែនការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្ម ប្រភពហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រទីផ្សារនៃផែនការអាជីវកម្ម
- លទ្ធភាពបង្កើតការងារធ្វើ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការកែច្នៃវត្ថុធាតុដើម ឬកសិផលក្នុងស្រុក ដែលត្រូវកំណត់ក្នុងកិច្ចសន្យា
- លទ្ធភាពផ្សារភ្ជាប់ និងគាំទ្រទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច
- ចំនួនទឹកប្រាក់ និងរបៀបបង់ថ្លៃប្រើប្រាស់ដីដែលអ្នកដាក់សំណើស្នើឡើង ។

លក្ខណវិនិច្ឆ័យសម្រាប់ការវាយតម្លៃ និងការចាត់ថ្នាក់សំណើ មិនអាចធ្វើការកែប្រែបានឡើយ ក្រោយពីចុះផ្សាយសេចក្តីជូនដំណឹងឱ្យដាក់សំណើដែលមានការអំពាវនាវ អនុលោមតាមមាត្រា ១០ នៃអនុក្រឹត្យនេះ ។

លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំ និងផ្សព្វផ្សាយអំពីការដាក់ពិន្ទុសម្រាប់ការចាត់ថ្នាក់សំណើនីមួយៗ តាមលំដាប់ ដោយផ្អែកលើលក្ខណវិនិច្ឆ័យខាងលើ ។

**មាត្រា ១៥ ..**

សំណើត្រូវដាក់នៅលេខាធិការដ្ឋានបច្ចេកទេស ក្នុងស្រោមសំបុត្របិទជិត និងមានចុះហត្ថលេខា ឬបោះត្រារបស់ម្ចាស់សំណើលើស្នាមបិទមុខសំបុត្រ ។

សំណើដែលបានទទួលក្រោយកាលបរិច្ឆេទបិទការទទួលសំណើ ត្រូវបង្វិលឱ្យម្ចាស់សំណើវិញ ដោយមិនត្រូវបើកស្រោមសំបុត្រឡើយ ។

សំណើទាំងអស់ ឬសំណើតែមួយ(០១)ដែលបានទទួល ត្រូវបើកជាសាធារណៈ តាមកាលបរិច្ឆេទដែលបានកំណត់ក្នុងសេចក្តីអញ្ជើញឱ្យដាក់សំណើមានការអំពាវនាវ ។ ម្ចាស់សំណើម្នាក់ៗមានសិទ្ធិចូលរួមមើលការបើកសំណើ ។

លេខាធិការដ្ឋានបច្ចេកទេស ត្រូវកំណត់សំណើណាដែលមានលក្ខណៈឆ្លើយតប ហើយពិនិត្យ និងលើកអនុសាសន៍លើសំណើនោះ ជូនទៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ដោយផ្អែកលើលក្ខណវិនិច្ឆ័យ ដែលចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យនេះ និងតាមនីតិវិធីដែលមានក្នុងឯកសារ ស្តីពីលក្ខខណ្ឌសម្រាប់ការដាក់សំណើ ។

**មាត្រា ១៦ ..**

បន្ទាប់ពីការពិចារណាលើអនុសាសន៍របស់លេខាធិការដ្ឋានបច្ចេកទេស អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវធ្វើការវាយតម្លៃ និងកំណត់បញ្ជីសង្ខេបតាមលំដាប់ថ្នាក់សំណើដែលមានលក្ខណៈឆ្លើយតបទាំងអស់ និងរៀបចំរបាយការណ៍វាយតម្លៃសំណើដែលមានលក្ខណៈឆ្លើយតប ហើយផ្តល់របាយការណ៍វាយតម្លៃនោះមួយច្បាប់ឱ្យម្ចាស់សំណើនីមួយៗ ។

**មាត្រា ១៧ .-**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា មិនត្រូវបានអនុញ្ញាតឱ្យធ្វើការចរចាលើលក្ខខណ្ឌចាំបាច់មួយចំនួន ដែលបានកំណត់ជាមុនថាមិនអនុញ្ញាតឱ្យចរចា នៅក្នុងឯកសារអំពាវនាវឱ្យដាក់សំណើនោះឡើយ ។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវអញ្ជើញម្ចាស់សំណើដែលជាប់លំដាប់ថ្នាក់ខ្ពស់ជាងគេ មកធ្វើការចរចាកិច្ចសន្យាសម្បទាន ។ ប្រសិនបើការចរចាមិនអាចឈានដល់ការសម្រេចបានកិច្ចសន្យាសម្បទាន ដោយមកពីអាជ្ញាធរមិនអាចទទួលយកលក្ខខណ្ឌដែលស្នើឡើងចុងក្រោយដោយម្ចាស់សំណើ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវបញ្ឈប់ការចរចាជាមួយម្ចាស់សំណើ ហើយត្រូវអញ្ជើញអ្នកដាក់សំណើដែលជាប់លំដាប់ថ្នាក់បន្ទាប់ មកធ្វើការចរចាកិច្ចសន្យាជាបន្តបន្ទាប់ ។

ប្រសិនបើការចរចាឈានដល់ការសម្រេចបាននូវសេចក្តីព្រាងកិច្ចសន្យាសម្បទាន អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវឱ្យម្ចាស់សំណើបំពេញលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២៣ នៃអនុក្រឹត្យនេះ ។

ក្នុងករណីដែលមានសំណើតែមួយ(០១) ឬពីរ(០២) លេខាធិការដ្ឋានបច្ចេកទេសក៏ត្រូវតែអនុវត្តតាមនីតិវិធី ដែលមានចែងក្នុងមាត្រាខាងលើដែរ ។

## ផ្នែកទី ២
## ការផ្តួចផ្តើមគម្រោងសម្បទានដីសេដ្ឋកិច្ចតាមរយៈសំណើមិនមានការអំពាវនាវ

**មាត្រា ១៨ .-**

វិធីសាស្ត្រអាទិភាពសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច គឺវិធីសាស្ត្រអំពាវនាវឱ្យដាក់សំណើក្នុងលក្ខណៈប្រកួតប្រជែង ប៉ុន្តែអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាសម្បទាន អាចធ្វើការពិចារណាលើសំណើសម្បទានដីសេដ្ឋកិច្ចដែលមិនមានការអំពាវនាវណាមួយបាន ក្នុងករណីម្ចាស់សំណើសន្យាផ្តល់អត្ថប្រយោជន៍ក្នុងលក្ខណៈពិសេស ដើម្បីសម្រេចនូវគោលបំណងនៃសម្បទានដីសេដ្ឋកិច្ច មានជាអាទិ៍ ÷

- ការនាំមកនូវបច្ចេកវិទ្យាថ្មី
- ការផ្សារភ្ជាប់ជាពិសេសរវាងសម្បទានដីសេដ្ឋកិច្ច ទៅនឹងសម្បទានដីសង្គមកិច្ច
- លទ្ធភាពពិសេសក្នុងការរកទីផ្សារកែច្នៃ ឬទីផ្សារនាំចេញ ។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា មិនត្រូវទទួលយកមកពិចារណានូវសំណើសម្បទានដីសេដ្ឋកិច្ចមិនមានការអំពាវនាវទេ ប្រសិនបើសំណើនោះទាក់ទងទៅនឹងដី ដែលជាកម្មវត្ថុនៃគម្រោងសម្បទានដីសេដ្ឋកិច្ចមានការអំពាវនាវ ដែលបានផ្សព្វផ្សាយសេចក្តីជូនដំណឹងឱ្យដាក់សំណើរួចហើយ ។

**មាត្រា ១៩ .-**

លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំពាក្យសុំសម្រាប់លើកសំណើមិនមានការអំពាវនាវ ដោយបញ្ចូល

សេចក្តីពណ៌នាសង្ខេប អំពីសាវតាផ្នែកអាជីវកម្ម និងហិរញ្ញវត្ថុរបស់ម្ចាស់សំណើ គោលគំនិត ស្តីពីការវិនិយោគដែលស្នើឡើង ព្រមទាំងព័ត៌មានទាក់ទងទៅនឹងទំហំដី និងទីតាំងដី ។

ម្ចាស់សំណើ អាចដាក់ពាក្យសុំសម្រាប់សំណើមិនមានការអំពាវនាវនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅអនុគណៈកម្មការវិនិយោគខេត្តក្រុង ឬនៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ។ ប្រសិនបើពាក្យសុំសម្រាប់សំណើមិនមានការអំពាវនាវ ត្រូវបានដាក់នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅអនុគណៈកម្មការវិនិយោគខេត្តក្រុង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មការវិនិយោគខេត្តក្រុង ត្រូវបញ្ជូនសំណើនោះទៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ក្នុងរយៈពេល ០៧ ( ប្រាំពីរ ) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលពាក្យសុំ ។

ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា សម្រេចធ្វើការពិចារណាសំណើមិនមានការអំពាវនាវ អាជ្ញាធរត្រូវធ្វើការពិគ្រោះយោបល់ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះត្រង់ចំណុចទី ៣ ។ បន្ទាប់មក អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវរៀបចំបំពេញលក្ខណវិនិច្ឆ័យសម្រាប់ការជ្រើសរើសដីធ្វើសម្បទាន ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ហើយស្នើឱ្យម្ចាស់សំណើផ្តល់ជូននូវឯកសារលំអិតនៃសំណើ ។

## មាត្រា ២០ .-

ឯកសារលំអិតនៃសំណើមិនមានការអំពាវនាវត្រូវបញ្ចូលព័ត៌មានដូចខាងក្រោម ÷

- ព័ត៌មានដូចមានចែងក្នុងមាត្រា ១២ នៃអនុក្រឹត្យនេះ និង
- របាយការណ៍នៃការសិក្សាវាយតម្លៃដំបូងអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម ។ ប្រសិនបើការសិក្សាវាយតម្លៃដំបូងបង្ហាញថា អាចមានហេតុប៉ះពាល់អវិជ្ជមានកម្រិតមធ្យម ឬខ្ពស់ សំណើនោះត្រូវបញ្ចូលរបាយការណ៍នៃការវាយតម្លៃពេញលេញអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម ។

## មាត្រា ២១ .-

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ដែលបានទទួលសំណើមិនមានការអំពាវនាវ ត្រូវអនុវត្តតាមបែបបទដូចតទៅ ÷

ក. អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវបញ្ជូនឯកសារលំអិតនៃសំណើមិនមានការអំពាវនាវទៅលេខាធិការដ្ឋានបច្ចេកទេស ឬទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ ។

ខ. លេខាធិការដ្ឋានបច្ចេកទេស ឬគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ត្រូវផ្តល់អនុសាសន៍ជូនអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ថាគួរ ឬមិនគួរធ្វើការចរចាកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច អនុលោមតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៣ ដល់មាត្រា ៥ នៃអនុក្រឹត្យនេះ ។

## មាត្រា ២២ .-

ការចរចាចុះកិច្ចសន្យាសម្រាប់គម្រោងសម្បទានមិនមានការអំពាវនាវ ត្រូវធ្វើក្នុងរយៈពេលយ៉ាងច្រើន ២៨

(ម្ភៃប្រាំបី) ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃផ្តើមការចរចា។ បើការចរចាមិនឈានដល់ការសម្រេចសេចក្តីព្រាងកិច្ចសន្យាសម្បទានក្នុងរយៈពេលកំណត់នេះទេ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាអាចបញ្ឈប់ការពិចារណាលើសំណើនោះ។

**មាត្រា ២៣ .-**

មុនចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច អ្នកដាក់សំណើត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២៤ .-**

លេខាធិការដ្ឋានបច្ចេកទេស ត្រូវរៀបចំទម្រង់ស្តង់ដារនៃកិច្ចសន្យាសម្បទាន ដែលត្រូវប្រើសម្រាប់រាល់សម្បទានដីសេដ្ឋកិច្ច ដោយត្រូវពិគ្រោះយោបល់ និងកំណត់ប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី ៤
## ការគ្រប់គ្រង និងការកែប្រែកិច្ចសន្យាសម្បទាន

**មាត្រា ២៥ .-**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវទទួលខុសត្រូវក្នុងការធានាឱ្យមានការអនុវត្តកិច្ចសន្យាសម្បទាន ដោយបង្កើតយន្តការ និងនីតិវិធីសម្រាប់ការត្រួតពិនិត្យតាមដានការអនុវត្តកិច្ចសន្យាសម្បទាន និងរាយការណ៍ជាប្រចាំអំពីការគ្រប់គ្រងកិច្ចសន្យាសម្បទាន ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយផ្តល់ព័ត៌មានដល់លេខាធិការដ្ឋានបច្ចេកទេស ឬគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យលើការអនុវត្តកិច្ចសន្យាសម្បទានរបស់សម្បទានិក និងទទួលព័ត៌មានពីសម្បទានិក និងពីក្រសួង ស្ថាប័នពាក់ព័ន្ធ ទាក់ទងនឹងការអនុវត្តកិច្ចសន្យាសម្បទាន។

**មាត្រា ២៦ .-**

មុននឹងធ្វើការកែប្រែកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងភាគីចុះកិច្ចសន្យា ដោយអនុលោមតាមបទប្បញ្ញត្តិ និងច្បាប់ជាធរមាន។

**មាត្រា ២៧ .-**

ការពន្យារ ការព្យួរ ការបញ្ចប់កិច្ចសន្យាសម្បទាន ត្រូវកំណត់ក្នុងកិច្ចសន្យាសម្បទាន។

## ជំពូកទី ៥
## យន្តការរដ្ឋបាល និងការអនុវត្តកិច្ចសន្យាសម្បទាន

**មាត្រា ២៨ .-**

យន្តការសម្បទានដីសេដ្ឋកិច្ច មានដូចខាងក្រោម ÷

- អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា

- លេខាធិការដ្ឋានបច្ចេកទេស
- គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង
- ក្រុមការងារដីរដ្ឋថ្នាក់ស្រុកខណ្ឌ
- ក្រុមប្រឹក្សាឃុំសង្កាត់។

**មាត្រា ២៩ ..**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិ និងទទួលខុសត្រូវក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច ដែលមានទុនវិនិយោគចាប់ពី ១០.០០០.០០០.០០០ (ដប់ពាន់លាន)រៀលឡើង ឬមានទំហំដីសម្បទានចាប់ពី ១.០០០ (មួយពាន់)ហិកតាឡើង។

អភិបាលខេត្ត ក្រុងមានសិទ្ធិ និងទទួលខុសត្រូវក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច ដែលមានទុនវិនិយោគក្រោម ១០.០០០.០០០.០០០ (ដប់ពាន់លាន)រៀល និងមានទំហំដីសម្បទានក្រោម ១.០០០ (មួយពាន់) ហិកតា។

**មាត្រា ៣០ ..**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា មានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- ផ្តួចផ្តើម និងរៀបចំឯកសារគម្រោងសម្បទានដីសេដ្ឋកិច្ចសម្រាប់អំពាវនាវឱ្យមានការដាក់សំណើ ឬអាចពិចារណាសំណើគម្រោងសម្បទានដីសេដ្ឋកិច្ច ដែលមិនមានការអំពាវនាវ
- វាយតម្លៃ និងកំណត់បញ្ជីសង្ខេបតាមលំដាប់ថ្នាក់សំណើ
- ចរចាលក្ខខណ្ឌសម្រាប់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- ដាក់ឱ្យអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- តាមដានការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- រាយការណ៍អំពីការគ្រប់គ្រងលើការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ជូនគណៈរដ្ឋមន្ត្រីជារៀងរាល់ ០៦ (ប្រាំមួយ)ខែម្តង និងតាមការចាំបាច់
- សម្របសម្រួល ប្រមូលព័ត៌មាន និងទិន្នន័យពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងការពារជាតិ ចំពោះ ដីក្នុងតំបន់អភិវឌ្ឍន៍យោធា លើលក្ខខណ្ឌដែលត្រូវដាក់បញ្ចូលក្នុងកិច្ចសន្យាសម្បទាន
- ពិនិត្យយោបល់របស់លេខាធិការដ្ឋានបច្ចេកទេសអំពីសំណើកែប្រែកិច្ចសន្យាសម្បទានណាមួយ និង៊
- បំពេញភារកិច្ចផ្សេងៗទៀតស្របតាមការចែងក្នុងអនុក្រឹត្យនេះ។

**មាត្រា ៣១ ..**

សមាសភាពនៃលេខាធិការដ្ឋានបច្ចេកទេស មានដូចខាងក្រោម ÷

-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធាន

-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

-តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

-តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

-តំណាងក្រសួងមហាផ្ទៃ សមាជិក

-តំណាងក្រសួងបរិស្ថាន សមាជិក

-តំណាងក្រសួងពាណិជ្ជកម្ម សមាជិក

-សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក

ប្រធាន និងសមាជិកនៃលេខាធិការដ្ឋានបច្ចេកទេស ត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល ។

មន្ត្រីជំនួយការរបស់លេខាធិការដ្ឋានបច្ចេកទេសត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់លេខាធិការដ្ឋានបច្ចេកទេស ។

លេខាធិការដ្ឋានបច្ចេកទេស មានទីតាំងនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៣២ .-**

លេខាធិការដ្ឋានបច្ចេកទេស មានភារកិច្ច ÷

- រៀបចំគម្រោងសម្បទានដីសេដ្ឋកិច្ច
- រៀបចំឯកសារអំពាវនាវឱ្យដាក់សំណើសម្បទានដីសេដ្ឋកិច្ច
- ផ្ដល់អនុសាសន៍ចំពោះសំណើសម្បទានដីសេដ្ឋកិច្ចទាំងអស់
- តាមដានការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- ផ្ដល់អនុសាសន៍អំពីការត្រួតពិនិត្យឡើងវិញនូវសម្បទានដែលមានស្រាប់ និង
- បំពេញភារកិច្ចផ្សេងៗទៀតស្របតាមការចែងក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៣ .-**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង មានតួនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ ។

**មាត្រា ៣៤ .-**

ក្រុមការងារដីរដ្ឋថ្នាក់ស្រុកខណ្ឌ មានតួនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា ២៨ នៃអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ ។

**មាត្រា ៣៥ .-**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវរៀបចំការពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី និងតំណាងប្រជាពលរដ្ឋមូលដ្ឋាន ក្រោយពីទទួលបានឯកសារលំអិតនៃគម្រោងសម្បទានដីសេដ្ឋកិច្ចមានការអំពាវនាវ ឬឯកសារ

លំអិតនៃសំណើមិនមានការអំពាវនាវ ដោយបញ្ជូនឯកសារនោះមួយច្បាប់ទៅឱ្យក្រុមប្រឹក្សាឃុំសង្កាត់ ដែលដីសម្បទានតាំងនៅ ដើម្បីពិនិត្យ និងផ្តល់យោបល់ក្នុងរយៈពេលយ៉ាងច្រើន ២៨ (ម្ភៃប្រាំបី) ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃដែលក្រុមប្រឹក្សាឃុំសង្កាត់បានទទួលសំណៅឯកសារលំអិតនៃគម្រោងសម្បទានមានការអំពាវនាវ ឬឯកសារលំអិតនៃសំណើមិនមានការអំពាវនាវ។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវពិចារណាលើមតិយោបល់របស់ក្រុមប្រឹក្សាឃុំសង្កាត់ពាក់ព័ន្ធ។ ក្នុងករណីបដិសេធយោបល់ក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវផ្តល់ហេតុផលច្បាស់លាស់។

## ជំពូកទី ៦

## ការត្រួតពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់

### មាត្រា ៣៦ .-

ចំពោះសម្បទានដីសេដ្ឋកិច្ចដែលបានផ្តល់ឱ្យមុនអនុក្រឹត្យនេះចូលជាធរមាន ហើយដែលកិច្ចសន្យាសម្បទាននោះនៅមានសុពលភាព ៖

- លេខាធិការដ្ឋានបច្ចេកទេសត្រូវបង្កើតសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃបន្ទាប់ពីមានសេចក្តីសម្រេចតែងតាំង និងត្រូវជូនដំណឹងក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ដល់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដីទាំងឡាយដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច និងក្រុមហ៊ុនសម្បទានទាំងអស់ឱ្យបានទូលំទូលាយ។
- ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីទាំងឡាយដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ឬសម្បទានិកទាំងអស់ត្រូវទទួលខុសត្រូវផ្តល់ព័ត៌មាន និងឯកសារថតចម្លងដែលពាក់ព័ន្ធ ដល់លេខាធិការដ្ឋានបច្ចេកទេសក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ បន្ទាប់ពីការជូនដំណឹង ឬការផ្សព្វផ្សាយសេចក្តីជូនដំណឹង ដើម្បីចុះក្នុងសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច។

### មាត្រា ៣៧ .-

ដោយមានជំនួយពីលេខាធិការដ្ឋានបច្ចេកទេស ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទានដែលមានស្រាប់ ត្រូវអនុវត្តនូវជំហានត្រួតពិនិត្យឡើងវិញ តាមស្ថានភាពនៃករណីនីមួយៗ ដូចខាងក្រោម ៖

- ការអនុវត្តរបស់សម្បទានិក ផ្អែកលើលក្ខខណ្ឌនៃកិច្ចសន្យាជាធរមាន ដោយពិចារណាលើកំរិតនៃការវិនិយោគដែលបានធ្វើរួចហើយ និងដែលគ្រោងធ្វើបន្ត
- ប្រាក់ចំណូល និងថ្លៃប្រើប្រាស់ដីតាមកិច្ចសន្យាសម្បទាន
- ធ្វើការពិគ្រោះយោបល់ជាសាធារណៈ ដើម្បីប្រមូលមតិយោបល់អំពីសកម្មភាពសម្បទានដីសេដ្ឋកិច្ច នៅឃុំសង្កាត់ ដែលដីសម្បទាននោះស្ថិតនៅ
- ប្រសិនបើសម្បទានិកម្នាក់កាន់កាប់ដីសម្បទានសរុបលើសពី ១០.០០០ (មួយម៉ឺន) ហិកតា ត្រូវស្នើឱ្យសម្បទានិកនោះស្ម័គ្រចិត្តកាត់ដីដែលលើសជូនរដ្ឋវិញ ឬប្រសិនបើសម្បទានិកមិនស្ម័គ្រចិត្តកាត់បន្ថយដីសម្បទាននោះទេ ត្រូវព្យាយាមចរចាលើការកាត់បន្ថយ

- ស្នើឱ្យមានការធ្វើនិយ័តកម្មដីនោះ ដូចមានចែងក្នុងមាត្រា ៤២ នៃអនុក្រឹត្យនេះ

- យោបល់របស់លេខាធិការដ្ឋានបច្ចេកទេស លើសេចក្តីព្រាងរបាយការណ៍ត្រួតពិនិត្យឡើងវិញ

- ក្នុងរយៈពេល ០៦ (ប្រាំមួយ)ខែ បន្ទាប់ពីការជូនដំណឹង ស្តីពីការបង្កើតសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យា ត្រូវដាក់របាយការណ៍ជូនគណៈរដ្ឋមន្ត្រី ដោយមានភ្ជាប់យោបល់របស់លេខាធិការដ្ឋានបច្ចេកទេស ទាក់ទងនឹងការត្រួតពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលខ្លួនបានចុះកិច្ចសន្យា ហើយបន្ទាប់មកទៀត របាយការណ៍នេះត្រូវធ្វើឡើងទៀងទាត់រៀងរាល់ ០៦ (ប្រាំមួយ)ខែម្តង

- នៅក្នុងអំឡុងពេល និងក្រោយពេលបញ្ចប់ការត្រួតពិនិត្យឡើងវិញ ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យា ត្រូវបន្តការតាមដានការអនុវត្តកិច្ចសន្យាដែលខ្លួនបានចុះហត្ថលេខា និងមិនត្រូវលុបចោល ឬមានបញ្ជាឱ្យផ្អាកដំណើរការ ហើយរាយការណ៍អំពីការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច លើកលែងតែមានសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីផ្ទុយពីនេះ ។

## មាត្រា ៣៨ .-

នីតិវិធីសម្រាប់ការកាត់បន្ថយទំហំដីសម្បទានសេដ្ឋកិច្ចដែលមានស្រាប់ ដោយស្ម័គ្រចិត្ត ឬដោយការចរចា ដូចមានចែងក្នុងមាត្រា ៥៩ នៃច្បាប់ភូមិបាល ត្រូវអនុវត្តដូចតទៅ ÷

- ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដី ដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ត្រូវស្នើឱ្យសម្បទានិកស្ម័គ្រចិត្តជ្រើសរើសចំណែកណាមួយនៃដីសម្បទានបង្វិលជូនរដ្ឋវិញ ស្របតាមមាត្រា ៤០ នៃអនុក្រឹត្យនេះ

- ប្រសិនបើសម្បទានិកមិនមានឆន្ទៈស្ម័គ្រចិត្តកាត់បន្ថយទំហំដីសម្បទាននោះទេ ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទាន ត្រូវអញ្ជើញសម្បទានិកមកចរចា អំពីផែនការប្រើប្រាស់ដីសម្បទាន ដោយមានជំនួយពីលេខាធិការដ្ឋានបច្ចេកទេស

- ប្រសិនបើការចរចាមិនសម្រេចបានជោគជ័យនៅក្នុងអំឡុងពេល ០៦ (ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃផ្តើមការចរចា ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទានត្រូវរាយការណ៍ ជូនទៅគណៈរដ្ឋមន្ត្រីតាមរយៈលេខាធិការដ្ឋានបច្ចេកទេស

- ប្រសិនបើសម្បទានិកខកខានមិនបានចូលមកចរចាក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលលិខិតអញ្ជើញឱ្យមកចរចាត្រូវបានបញ្ជូនដល់អាស័យដ្ឋាន ឬដល់ដៃសម្បទានិក ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទាន ត្រូវរាយការណ៍ជូនគណៈរដ្ឋមន្ត្រី ដើម្បីមានវិធានការ ។

## មាត្រា ៣៩ .-

គណៈរដ្ឋមន្ត្រី មានសិទ្ធិលើកលែងការកាត់បន្ថយការកាន់កាប់សម្បទានដីសេដ្ឋកិច្ច ដែលមានទំហំសរុបលើសពី ១០.០០០ (មួយម៉ឺន) ហិកតា ក្នុងករណីដូចខាងក្រោម ÷

- ដីសម្បទាននោះត្រូវបានផ្តល់ឱ្យមុនពេលដែលច្បាប់ភូមិបាលឆ្នាំ ២០០១ ចូលជាធរមាន

-ការកាត់បន្ថយដីសម្បទាននោះ នាំឱ្យខូចប្រយោជន៍អាជីវកម្មដែលកំពុងមានដំណើរការនៅពេលដែលច្បាប់ភូមិបាលចូលជាធរមាន ។ ការកាប់ឆ្ការដើមឈើ ឬការដុតព្រៃសំអាតដី មិនត្រូវបានចាត់ទុកជាអាជីវកម្មកំពុងដំណើរការ ឬជាការបំពេញតាមលក្ខខណ្ឌនៃការអភិវឌ្ឍដីដែលចែងក្នុងកិច្ចសន្យាឡើយ ។

## មាត្រា ៤០ .-

យោបល់របស់លេខាធិការដ្ឋានបច្ចេកទេសលើសេចក្តីព្រាងរបាយការណ៍ត្រួតពិនិត្យឡើងវិញ លើសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់នីមួយៗ ដែលផ្តល់ជូនទៅក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទាន ត្រូវមានបញ្ជាក់សេចក្តី ដូចខាងក្រោម ÷

- កិច្ចសន្យានោះកំពុងដំណើរការដោយពេញលេញ
- កិច្ចសន្យានោះគួរមានការកែប្រែលើចំណុចជាក់លាក់ ដោយបញ្ជាក់អំពីកិច្ចការដែលត្រូវបំពេញដោយភាគីនៃកិច្ចសន្យា ដើម្បីទទួលយកបានទាំងសង្ខាង
- គួរលុបចោលកិច្ចសន្យានោះ ដោយមូលហេតុសម្បទានិកបានបំពានលើកិច្ចសន្យា
- ចំពោះដីសម្បទានលើសពី ១០.០០០ (មួយម៉ឺន) ហិកតា ត្រូវបញ្ជាក់អំពីការស្ម័គ្រចិត្តកាត់បន្ថយទំហំដីដោយសម្បទានិក ឬត្រូវធ្វើការចរចាដើម្បីកាត់បន្ថយ ឬហេតុផលចាំបាច់សម្រាប់ការលើកលែងការកាត់បន្ថយដីសម្បទាន ។ ការជ្រើសរើសដីសម្រាប់កាត់បន្ថយ ត្រូវបញ្ចូលផ្នែកដែលមានទំនាស់ ផ្នែកដែលមិនទាន់បានកាប់ឆ្ការ ផ្នែកដែលមិនទាន់បានអភិវឌ្ឍ និងផ្នែកដែលជាដីសាធារណៈរបស់រដ្ឋ ។

## មាត្រា ៤១ .-

របាយការណ៍ត្រួតពិនិត្យ អនុសាសន៍របស់លេខាធិការដ្ឋានបច្ចេកទេស និងលទ្ធផលចុងក្រោយនៃការត្រួតពិនិត្យឡើងវិញលើសម្បទាននីមួយៗ ត្រូវរក្សាទុកជាឯកសារសាធារណៈ នៅលេខាធិការដ្ឋានបច្ចេកទេស និងនៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ។

## មាត្រា ៤២ .-

ក្នុងការត្រួតពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធ្វើនិយ័តកម្មដីក្នុងតំបន់ដីសម្បទាន ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យឡើងវិញ ។ ការធ្វើនិយ័តកម្មដីមានរាប់បញ្ចូលការកែតម្រូវក្បាលដី ការវិនិច្ឆ័យសិទ្ធិលើដីធ្លីរបស់អ្នកកាន់កាប់ក្បាលដីក្នុងតំបន់ត្រួតពិនិត្យឡើងវិញ និងការចុះបញ្ជីក្បាលដីតាមនីតិវិធីជាធរមាន ។

## ជំពូកទី ៧
## ប្រភពធនធាន

**មាត្រា ៤៣ .-**

ថវិកាសម្រាប់ប្រតិបត្តិការរបស់លេខាធិការដ្ឋានបច្ចេកទេស ត្រូវស្ថិតក្នុងកញ្ចប់ថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ស្របតាមប្រព័ន្ធថវិកាឯកភាព ធនធាន និងថវិការបស់លេខាធិការដ្ឋានបច្ចេកទេសបានមកពីថវិកាជាតិ និងហិរញ្ញប្បទានដែលបានមកពីប្រភពក្នុងស្រុក ឬក្រៅស្រុក ឬពីអ្នកផ្តល់ជំនួយអន្តរជាតិ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៤៤ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន និងអភិបាលខេត្តក្រុងទាំងអស់ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ... ឆ្នាំ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ៤៥
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១._**

ត្រូវបានផ្ទេរតំបន់ព្រៃការពារនិងអភិរក្សព្រៃឈើចំនួន១៣កន្លែងដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនក្រសួងបរិស្ថាន ដើម្បីគ្រប់គ្រងបន្ត។

**មាត្រា២._**

ត្រូវបានផ្ទេរតំបន់ព្រៃផ្តល់ផលចំនួន៥កន្លែងដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនក្រសួងបរិស្ថាន ដើម្បីគ្រប់គ្រងបន្ត ហើយក្រសួងបរិស្ថាន ត្រូវបន្តនីតិវិធីក្នុងការដាក់បញ្ចូលព្រៃផ្តល់ផលទាំង៥កន្លែងនេះ ជាតំបន់ការពារ និងអភិរក្សព្រៃឈើ។

**មាត្រា៣._**

ត្រូវបានផ្ទេរតំបន់សម្បទានដីសេដ្ឋកិច្ចចំនួន៧៣កន្លែងដូចមានក្នុងឧបសម្ព័ន្ធ៣នៃអនុក្រឹត្យនេះ ពីក្រសួងបរិស្ថាន ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីគ្រប់គ្រងបន្ត។

**មាត្រា៤._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ ១ នៃអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១៦

| លរ | ព្រៃការពារ និងតំបន់អភិរក្ស | ផ្ទៃដី(ហិកតា) | ទីតាំង | ក្របខណ្ឌច្បាប់ |
|---|---|---|---|---|
| ១ | តំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀលអាងត្រពាំងថ្ម | ១២.៦៥០ | បន្ទាយមានជ័យ | ព្រះរាជក្រឹត្យលេខ ០២០០/១១០ ២២-កុម្ភៈ-២០០០ |
| ២ | តំបន់គ្រប់គ្រងធនធានធម្មជាតិ តំបន់ព្រៃកោងកាងទឹកសាបនៅក្រុងព្រះសីហនុ | ៦.២០២ | ព្រះសីហនុ | អនុក្រឹត្យលេខ ៧៦ ២០-វិច្ឆិកា-១៩៩៧ |
| ៣ | តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ "ព្រះវិហារ" | ១៩០.០២៧ | ព្រះវិហារ | អនុក្រឹត្យលេខ ៧៦ ៣០-កក្កដា-២០០២ |
| ៤ | តំបន់ព្រៃការពារអភិរក្សជីវចម្រុះ ជួរភ្នំក្រវាញភាគកណ្ដាលនិងជីវចម្រុះ | ៤០១.៣១៣ | កោះកុង, ពោធិ៍សាត់ និងកំពង់ស្ពឺ | អនុក្រឹត្យលេខ ៧៧ ៣០-កក្កដា-២០០២ |
| ៥ | តំបន់ព្រៃការពារសម្រាប់អភិរក្សជីវចម្រុះ ការពារច្រករបៀងសត្វដំរី និងមជ្ឈមណ្ឌលស្ដារលទ្ធភាពដែលទ្រទ្រង់លក្ខណៈជីវសាស្ត្រសត្វព្រៃកោះកុង | ១៤៤.២៧៥ | កោះកុង | អនុក្រឹត្យលេខ ៦៥ ០៦-តុលា-២០០៤ |
| ៦ | តំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀល និងសត្វស្លាបផ្សេងទៀត ស្ថិតនៅបឹងព្រែកល្ពៅ ស្រុកបុរីជលសារ ស្រុកកោះអណ្ដែត ខេត្តតាកែវ | ៨.៣០៥ | តាកែវ | អនុក្រឹត្យលេខ ១៤៩ ១៥-តុលា-២០០៧ |
| ៧ | តំបន់ព្រៃការពារសម្រាប់ល្បែងកម្សាន្ត និងកីឡាប្រមាញ់ វារយ៉ាដាវ ខេត្តរតនគិរី | ១០១.៣៤៨ | រតនគិរី | អនុក្រឹត្យលេខ ៨៧ ២៣-មីនា-២០០៩ |

| | | | | |
|---|---|---|---|---|
| ៨ | តំបន់ព្រៃការពារ និងអភិរក្សជីវចម្រុះសីមា ខេត្តមណ្ឌលគិរី និងក្រចេះ | ២៩២.៦៩០ | មណ្ឌលគិរី និងក្រចេះ | អនុក្រឹត្យលេខ ១៤៣ ០២-កញ្ញា-២០០៩ |
| ៩ | តំបន់គ្រប់គ្រងនិងអភិរក្សដែនបម្រុងសត្វក្រៀលនិងសត្វស្លាបផ្សេងៗ ស្ថិតនៅទីតាំងអន្លង់ព្រីង ស្រុកកំពង់ត្រាច ខេត្តកំពត | ២១៧ | កំពត | អនុក្រឹត្យលេខ ០៤ ០៦-មករា-២០១១ |
| ១០ | តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ " មណ្ឌលគិរី " | ៤២៩.៤៣៨ | មណ្ឌលគិរី | អនុក្រឹត្យលេខ ៧៩ ៣០-កក្កដា-២០០២ |
| ១១ | តំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃសៀមប៉ាង ខេត្តស្ទឹងត្រែង | ៦៦.៩៣២ | ស្ទឹងត្រែង | អនុក្រឹត្យលេខ ៧៧ ២៥-កុម្ភៈ-២០១៤ |
| ១២ | តំបន់ព្រៃការពារសម្រាប់អភិរក្សព្រៃឈើ និងសត្វព្រៃ"ពញាក្រែក" ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ | ១៩៩ | ត្បូងឃ្មុំ | អនុក្រឹត្យលេខ ២៧ ១០-កុម្ភៈ-២០១៦ |
| ១៣ | តំបន់គ្រប់គ្រងនិងអភិរក្សសត្វខ្សឹបនិងជីវចម្រុះនៃប្រព័ន្ធអេកូឡូស៊ីរួម ក្នុងភូមិសាស្ត្រកំពង់ធំ និងសៀមរាប | ៣១.១៥៩ | កំពង់ធំ និង សៀមរាប | ប្រកាសលេខ ៦៤ ០៨-កុម្ភៈ-២០១០ |

ឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១៦

| ល.រ | ទីតាំងព្រៃ | ខេត្ត | ផ្ទៃដី(ហិកតា) |
|---|---|---|---|
| ១ | ព្រៃឡង់ | ក្រចេះ ស្ទឹងត្រែង និងកំពង់ធំ | ៣០៥.៣៦៦ |
| ២ | ព្រៃក្រករបៀងក្រវាញខាងត្បូង | កំពង់ស្ពឺ ពោធិ៍សាត់ និងកោះកុង | ៤៤៣.១៣៤ |
| ៣ | ព្រៃព្រះរការ | ព្រះវិហារ | ៨០.៨២៣ |
| ៤ | ព្រៃសៀមប៉ាងលិច | ស្ទឹងត្រែង | ៦៥.០៧០ |
| ៥ | ព្រៃវើនសៃ-សៀមប៉ាង | ស្ទឹងត្រែង និង រតនគិរី | ៥៦.៨៣២ |


ផែនទី តំបន់ការពារធ ជាតិ ២០១៦
កំណត់សំគាល់
0 50 100 km
Map Coordinate System
Unit: meter
Datum: WGS 1984

ឧបសម្ព័ន្ធ ៣ នៃអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១៦

| ល.រ | ឈ្មោះក្រុមហ៊ុន | ទំហំផ្ទៃដី (ហិកតា) | ទីតាំង | អនុក្រឹត្យកំណត់តំបន់ | អនុក្រឹត្យអនុបយោគ |
|---|---|---|---|---|---|
| ១ | Vietnam Kampuchea Economy Trade and Industry Company Limited (VKETI) Co., Ltd | ៩០៥៥ | ស្នួល(ក្រចេះ) | ១៧៣អនក្រ.បក-១៤-តុលា-២០០៩ | ០៣អនក្រ.បក-០៥-មករា-២០១០ |
| ២ | ក្រាចញៀម ហ៊ីបធន ឌូវី ហ្វាន ឡៀន ជាយណាម-កម្ពុជា | ២៦១៦ | ស្នួល(ក្រចេះ) | ១៧៣អនក្រ.បក-១៤-តុលា-២០០៩ | ០៦អនក្រ.បក-០៨-មករា-២០១០ |
| ៣ | HLH AGRICULTURE Cambodia Co., Ltd | ៩៩៨៥ | ឱរ៉ាល់(កំពង់ស្ពឺ) | ២៨អនក្រ.បក-២៤-កុម្ភៈ-២០១០ | ៤០អនក្រ.បក-១៣-មេសា-២០១០ |
| ៤ | YELLOW FIELD (Cambodia) International Limited | ៨៨៩១ | ឱរ៉ាល់(កំពង់ស្ពឺ) | ០៥អនក្រ.បក-០៨-មករា-២០១០ | ២១អនក្រ.បក-២៥-មករា-២០១០ |
| ៥ | GREAT FIELD (Cambodia) International Limited | ៩០៨៥ | ឱរ៉ាល់(កំពង់ស្ពឺ) | ០៥អនក្រ.បក-០៨-មករា-២០១០ | ១៩អនក្រ.បក-២៥-មករា-២០១០ |
| ៦ | សេរីវុឌ្ឍ ខូ លីមីធីត | ៤២៧៣ | ណាមលៀរ (មណ្ឌលគិរី) | ៣៧អនក្រ.បក-១៣-កុម្ភៈ-២០០៩ | ៣៧អនក្រ.បក-១៧-កុម្ភៈ-២០០៩ |
| ៧ | L.Y.P Group Co.,Ltd ផ្ទេរកម្មសិទ្ធិ(ស៊ី ពិន អេសិ អេហ្ស៊ីខលឈឺ) | ៤១០០ | បូទុមសាគរ (ខេត្តកោះកុង) | ៣១អនក្រ.បក-១២-មីនា-២០១០ | ៣៨អនក្រ.បក-១៣-មេសា-២០១០ |
| ៨ | កោះកុង អេស អ៊ី ហ្ស៊ីន ខូអិលធីឌី ផ្ទេរកម្មសិទ្ធិ(កោះកុង ឆិបបើ ផ្លេនធេសិន) | ៩៩៧៣ | បូទុមសាគរ (កោះកុង) | ១៣៣អនក្រ.បក-២០-សីហា-២០០៩ | ១៤៩អនក្រ.បក-៣០-តុលា-២០០៩ |
| ៩ | ស៊ី.អេ.ស៊ី.អេ ២ | ៧២៨៩ | បឹងផែ(កំពង់ធំ) | ១៩៩អនក្រ.បក-២៤-វិច្ឆិកា-២០០៩ | ០៤អនក្រ.បក-០៨-មករា-២០១០ |
| ១០ | ហៀង ហៀក ម៉ិនអាសេនស ខូអិលធីឌី | ៤៣០៥ | បឹងផែ(កំពង់ធំ) | ២២៣អនក្រ.បក-១៦-ធ្នូ-២០០៩ | ២០អនក្រ.បក-២៥-មករា-២០១០ |
| ១១ | CAOUTCHOUC MEKONG | ៨០០០ | បឹងផែ(កំពង់ធំ) | ៨៦អនក្រ.បក-០៦-ឧសភា-២០១០ | ៨៨អនក្រ.បក-១៧-មិថុនា-២០១០ |
| ១២ | សុវណ្ណភូមិ ខូអិលធីឌី | ៦៨២៥ | ស្នួល(ក្រចេះ មណ្ឌលគិរី) | ១៧៣អនក្រ.បក-១៤-តុលា-២០០៩ | ០៥អនក្រ.បក-០៨-មករា-២០១០ |
| ១៣ | E-Investment (Cambodia) Ltd | ៦៨៥០ | ស្នួល(ក្រចេះ) | ១២៨អនក្រ.បក-១៣-សីហា-២០០៩ | ១៨៨អនក្រ.បក-៣០-តុលា-២០០៩ |
| ១៤ | សំណាងអង្គរ និងឡុបអេន | ១២២៤ | ស្នួល(ក្រចេះ) | ១២៨អនក្រ.បក-១៣-សីហា-២០០៩ | ១៨៣អនក្រ.បក-៣០-តុលា-២០០៩ |
| ១៥ | ចំការកៅស៊ូមេមត់ ខូ អិលធីឌី | ៩៨៥៥ | ស្នួល(ក្រចេះ) | ១៧៣អនក្រ.បក-១៤-តុលា-២០០៩ | ១២៧អនក្រ.បក-២៨-កញ្ញា-២០០៩ |
| ១៦ | សាយនុង កៅស៊ូ ឌុកនុង ខូ អិលធីឌី | ១៨៥២ | ស្នួល(ក្រចេះ) | ៣៩៨សជណ-៣០-មីនា-២០១១ | |

| | | | | | |
|---|---|---|---|---|---|
| ១៧ | ឫទ្ធី ក្រានីត | ១៦៥៦ | បឹងពែរ(ព្រះវិហារ) | ១៧អនក្រ.បក-២៥-មករា-២០១១ | ៥២អនក្រ.បក-២១-មីនា-២០១១ |
| ១៨ | ស៊ី.អេ.ស៊ី.អេ ២ | ១៥៤៦ | បឹងពែរ(កំពង់ធំ-សៀមរាប) | ១៧អនក្រ.បក-២៥-មករា-២០១១ | ៥៣អនក្រ.បក-២១-មីនា-២០១១ |
| ១៩ | ហៀង ហៀក អ៊ិនវេសមេន ខូអិលធីឌី | ៥០៥៥ | បឹងពែរ(កំពង់ធំ-ព្រះវិហារ(សៀមរាប) | ១៧អនក្រ.បក-២៥-មករា-២០១១ | ៥០អនក្រ.បក-២១-មីនា-២០១១ |
| ២០ | សុវណ្ណ ទ្រី ខូ អិលធីឌី | ៥០០០ | ស្នួល(ក្រចេះ) | ១៥៤អនក្រ.បក-០៦-ធ្នូ-២០១០ | ៤៩អនក្រ.បក-២១-មីនា-២០១១ |
| ២១ | ម្លប់ពោធិ៍ អភិវឌ្ឍន៍ កសិ-ឧស្សាហកម្ម | ១៩៥០ | លំផាត់(រតនៈគីរី) | ៤២អនក្រ.បក-១៤-មីនា-២០១១ | ៨៧អនក្រ.បក-២០-ឧសភា-២០១១ |
| ២២ | ស៊ី មុនី គ្រេនស្ទ័ររ៉េស៊ីន & ខនស្ត្រាក់សិន | ៦៨៧០ | គូលែន(សៀមរាប-ព្រះវិហារ) | ១១៤អនក្រ.បក-១៥-មិថុនា-២០១១ | ១៦៦អនក្រ.បក-២២-កក្កដា-២០១១ |
| ២៣ | ជុំពេញ អាហ្គ្រិក ខូអិលធីឌី | ៨៨២៥ | លំផាត់(រតនៈគីរី) | ៤៣អនក្រ.បក-១៤-មីនា-២០១១ | ៨៦អនក្រ.បក-២០-ឧសភា-២០១១ |
| ២៤ | VIRTUS GREEN PLANTATIONS (CAMBODIA) PTE., LTD | ៦៧១៨ | បូកគោ (កំពត) | ៣១អនក្រ.បក-២២-កុម្ភៈ-២០១១ | ៨៨អនក្រ.បក-២០-ឧសភា-២០១១ |
| ២៥ | ជាតា រ៉ាប់ប៊ើរ(ខេមបូឌា) ខូអិលធីឌី | ៧៧០០ | គូលែន(ឧត្តរមានជ័យ) | ១១២អនក្រ.បក-១៤-មិថុនា-២០១១ | ១៦៨អនក្រ.បក-២២-កក្កដា-២០១១ |
| ២៦ | ទូម៉ាទិ រ៉ាប់ប៊ើរ ខូអិលធីឌី | ៧៧៥០ | គូលែន(ឧត្តរមានជ័យ) | ១១២អនក្រ.បក-១៤-មិថុនា-២០១១ | ១៦៩អនក្រ.បក-២២-កក្កដា-២០១១ |
| ២៧ | HOANG ANH ANDONG MEAS Co., Ltd | ៩៤៧០ | លំផាត់(រតនៈគីរី) | ៦៨អនក្រ.បក-២០-មេសា-២០១១ | ១៥៩អនក្រ.បក-១៨-កក្កដា-២០១១ |
| ២៨ | ឌី សេង ខូ អិលធីឌី | ២៤៣២ | បូកគោ(ព្រះសីហនុ) | ១២៨អនក្រ.បក-១៣-សីហា-២០០៩ | ១៨៧អនក្រ.បក-៣០-តុលា-២០០៩ |
| ២៩ | សល សុភា ពាណិជ្ជ គ្រុប ខូអិលធីឌី | ២៩៥៥ | បឹងពែរ(កំពង់ធំ) | ១៩៨អនក្រ.បក-២៥-សីហា-២០១១ | ២៤០អនក្រ.បក-២៨-តុលា-២០១១ |
| ៣០ | MDS Import Export Co., Ltd | ៦៣៩២ | សំកុស(ពោធិ៍សាត់) | ១៧៦អនក្រ.បក-៣០-ធ្នូ-២០១០ | ១០អនក្រ.បក-១២-មករា-២០១១ |
| ៣១ | ប្រ៊ី ភាព អ៊ីមផត អ៊ិចផត | ៩៩១៦ | បឹងពែរ(ព្រះវិហារ) | ៨២អនក្រ.បក-១៥-ឧសភា-២០១១ | ១៦៣អនក្រ.បក-២២-កក្កដា-២០១១ |
| ៣២ | ហួត ណេងរីតា ខូអិលធីឌី | ៣០០០ | គូលែន (ឧត្តរមានជ័យ) | ១៨២អនក្រ.បក-១១-សីហា-២០១១ | ២៤៣អនក្រ.បក-២៨-តុលា-២០១១ |
| ៣៣ | អាន ម៉ាទីគ្រុប | ៩៩៩៣ | បឹងពែរ(កំពង់ធំ-ព្រះវិហារ) | ៩៧អនក្រ.បក-១២-សីហា-២០១០ | ១០២អនក្រ.បក-១៩-សីហា-២០១០ |
| ៣៤ | កំពង់ស្ពឺ ស៊ូហ្គឺ (ផ្ទេរគម្រោងទៅឱ្យ កំពង់ស្ពឺផ្លេនថេសិន) | ៤៧០០ | ឱរ៉ាល់(កំពង់ស្ពឺ) | ១៧អនក្រ.បក-២៥-មករា-២០១១ | ៤៧អនក្រ.បក-២១-មីនា-២០១១ |
| ៣៥ | ជាតិ អភិវឌ្ឍន៍ ខូអិលធីឌី | ៦០០០ | បន្ទាយឆ្មារ(ឧត្តរមានជ័យ-បន្ទាយមានជ័យ) | ២២អនក្រ.បក-០១-កុម្ភៈ-២០១១ | ៤៨អនក្រ.បក-២១-មីនា-២០១១ |

| | | | | | |
|---|---|---|---|---|---|
| ៣៦ | ខេមបូឌា ឈិនផ្លេនថេសិន អិលធីឌី | ៩២៣៧ | គូលែន(ព្រះវិហារ) | ២០៦អនក្រ.បក-០៧-កញ្ញា-២០១១ | ២៨១អនក្រ.បក-១៣-ធ្នូ-២០១១ |
| ៣៧ | EXCEL CATOR PLANTATION Co., Ltd | ៧៨៧២ | គូលែន (សៀមរាប) | ២៥០អនក្រ.បក-ទី០៨-វិច្ឆិកា-២០១១ | ២៨៣អនក្រ.បក-១៣-ធ្នូ-២០១១ |
| ៣៨ | Best Royal (K) Co., LTD | ៦៥០០ | គូលែន(ឧត្តរមានជ័យ-ព្រះវិហារ) | ២៦៣អនក្រ.បក-២៣-វិច្ឆិកា-២០១១ | ០៧អនក្រ.បក-១៨-មករា-២០១២ |
| ៣៩ | តែនីញ សៀមរាប អភិវឌ្ឍន៍កៅស៊ូ ខូអិលធីឌី | ៧៦០០ | គូលែន(ឧត្តរមានជ័យ) | ២៦៤អនក្រ.បក-២៣-វិច្ឆិកា-២០១១ | ០៦អនក្រ.បក-១៨-មករា-២០១២ |
| ៤០ | HOANG ANH LUMPHAT Co., Ltd | ៩១៧៣ | លំផាត់(រតនៈគិរី) | ២៥៩អនក្រ.បក-០៨-វិច្ឆិកា-២០១១ | ០៥អនក្រ.បក-១៨-មករា-២០១២ |
| ៤១ | ១១ អភិវឌ្ឍន៍ កសិកម្ម ខូ អិលធីឌី | ១៨០០ | ឱរ៉ាល់(កំពង់ស្ពឺ) | ១៦អនក្រ.បក-២៦-មករា-២០១២ | ២២អនក្រ.បក-០៦-កុម្ភៈ-២០១២ |
| ៤២ | សម្បត្តិផ្ទើមជីលើម | ២៤៩៦ | បឹងកែ(កំពង់ធំ) | ១៨៦អនក្រ.បក-១២-សីហា-២០១១ | ២៣៨អនក្រ.បក-១២-សីហា-២០១១ |
| ៤៣ | សួន មាន សម្បត្តិ ខូអិលធីឌី | ៤០៥៥ | ទេមជ័យសរ(បាត់ដំបង) | ៦៣អនក្រ.បក-០៦-មេសា-២០១១ | ៩៤អនក្រ.បក-២៤-ឧសភា-២០១១ |
| ៤៤ | Investment and Development Dai Thanh (Cambodia) JSC Ltd | ៨៧០៨ | ភ្នំព្រេច(មណ្ឌលគិរី) | ៩៨អនក្រ.បក-៣០-ឧសភា-២០១១ | ១៦៤អនក្រ.បក-២២-កក្កដា-២០១១ |
| ៤៥ | លឹម ឈុង ខូអិលធី | ៣២១ | នងកែង (កោះកុង) | ២៧៨អនក្រ.បក-១៣-ធ្នូ-២០១១ | ៤២អនក្រ.បក-១៦-មីនា-២០១២ |
| ៤៦ | សេ ហុង ផ្លេនថេសិន លីមីធីត | ៩៧០០ | គូលែន(ឧត្តរមានជ័យ-ព្រះវិហារ) | ៨៥អនក្រ.បក-១១-មេសា-២០១២ | ៨៧អនក្រ.បក-០៧-មិថុនា-២០១២ |
| ៤៧ | ឈុន លឹម គ្រុប | ៣០០០ | បន្ទាយឆ្មារ (បន្ទាយមានជ័យ) | ២៥៧អនក្រ.បក-០៨-វិច្ឆិកា-២០១១ | ២៨២អនក្រ.បក-១៣-ធ្នូ-២០១១ |
| ៤៨ | វិឡាឌីឡុបមេន ខូអិលធីឌី | ៧២៥ | ភ្នំព្រេច (មណ្ឌលគិរី) | ៦១អនក្រ.បក-០១-មេសា-២០១១ | ៩៣អនក្រ.បក-២៤-ឧសភា-២០១១ |
| ៤៩ | K-Peace Investment Cambodia Co., Ltd | ៨០០ | ណាមលៀ (មណ្ឌលគិរី) | ១៣អនក្រ.បក-២០-មករា-២០១១ | ២៨អនក្រ.បក-២១-កុម្ភៈ-២០១២ |
| ៥០ | ទេពី អញ្ញ វិនិយោគ | ១០០០ | បឹងកែ(កំពង់ធំ) | ១៧៧អនក្រ.បក-០២-សីហា-២០១១ | ២២៨អនក្រ.បក-០៥-តុលា-២០១១ |
| ៥១ | ធី សុខន អ៊ិនខមហ្វីឌសិន | ៩០០០ | លំផាត់(រតនៈគិរី) | ៨០អនក្រ.បក-០៧-មិថុនា-២០១២ | ១៣៣អនក្រ.បក-២៤-សីហា-២០១២ |
| ៥២ | លឹម រ៉ូប៉ាល់ ជីញ ស្ពក | ៩០៦៨ | ភ្នំព្រេច(មណ្ឌលគិរី) | ៧៩អនក្រ.បក-០៧-មិថុនា-២០១២ | ២៤៩អនក្រ.បក-១២-ធ្នូ-២០១២ |
| ៥៣ | ជី ឈុង សំណង់&អេហារ៉ែណ នីហារ៉ែណ ផ្លេរឡ (Green Rubber Development Plantation) | ៦០០០ | គូលែន (សៀមរាប-ព្រះវិហារ) | ៦៣អនក្រ.បក-២៣-មេសា-២០១២ | ១៦១ អនក្រ.បក-២២-កក្កដា-២០១១ |
| ៥៤ | MEGA FIRST CORPORATION BERHAD | ៩៤៧៧ | ណាមលៀ (មណ្ឌលគិរី) | ៦១ អនក្រ.បក -១៨-មេសា-២០១២ | ៨៤អនក្រ.បក -០៣-មិថុនា-២០១២ |

| | | | | | |
|---|---|---|---|---|---|
| ៣៦ | ខេមបូឌា ឈានឡុងដេវេឡុបមិន លីមីធីត | ៩២៣៧ | គូលែន(ព្រះវិហារ) | ២០៦អនក្រ.បក-០៧-កញ្ញា-២០១១ | ២៨១អនក្រ.បក-១៣-ធ្នូ-២០១១ |
| ៣៧ | EXCEL CATOR PLANTATION Co., Ltd | ៧៨៧២ | គូលែន (សៀមរាប) | ២៥៨អនក្រ.បក-ទី០៨-វិច្ឆិកា-២០១១ | ២៨៣អនក្រ.បក-១៣-ធ្នូ-២០១១ |
| ៣៨ | Best Royal (K) Co., LTD | ៦៥០០ | គូលែន(ឧត្តរមានជ័យ-ព្រះវិហារ) | ២៦៣អនក្រ.បក-២៣-វិច្ឆិកា-២០១១ | ០៧អនក្រ.បក-១៨-មករា-២០១២ |
| ៣៩ | តៃនីញ សៀមរាប អភិវឌ្ឍន៍កៅស៊ូ ខូអិលធីឌី | ៧៦០០ | គូលែន(ឧត្តរមានជ័យ) | ២៦៤អនក្រ.បក-២៣-វិច្ឆិកា-២០១១ | ០៦អនក្រ.បក-១៨-មករា-២០១២ |
| ៤០ | HOANG ANH LUMPHAT Co., Ltd | ៩១៧៣ | លំផាត់(រតនៈគីរី) | ២៥៩អនក្រ.បក-០៨-វិច្ឆិកា-២០១១ | ០៥អនក្រ.បក-១៨-មករា-២០១២ |
| ៤១ | ធី អេ អភិវឌ្ឍន៍ កសិកម្ម ខូ លីមីធីត | ១៤០០ | ឱរ៉ាល់(កំពង់ស្ពឺ) | ១៦អនក្រ.បក-២៦-មករា-២០១២ | ២២អនក្រ.បក-០៦-កុម្ភៈ-២០១២ |
| ៤២ | សម្បត្តិផ្ទៃពិណែម | ២៤៥៦ | បឹងកែរ(កំពង់ធំ) | ១៨៦អនក្រ.បក-១២-សីហា-២០១១ | ២៣៨អនក្រ.បក-១២-សីហា -២០១១ |
| ៤៣ | សុខ មាន សម្បត្តិ ខូអិលធីឌី | ៤០៩៥ | រនាមដូនសំ(បាត់ដំបង) | ៦៣អនក្រ.បក-០៦-មេសា-២០១១ | ៩៨អនក្រ.បក-២៤-ឧសភា-២០១១ |
| ៤៤ | Investment and Development Dai Thanh (Cambodia) JSC Ltd | ៨៧០៨ | ភ្នំក្រោល(មណ្ឌលគិរី) | ៩៨អនក្រ.បក-៣០-ឧសភា -២០១១ | ១៦៨អនក្រ.បក-២២- កក្កដា-២០១១ |
| ៤៥ | លីម ស៊ុង ខូអិលធី | ៣២១ | ដងតង់ (កោះកុង) | ២៧៨អនក្រ.បក-១៣-ធ្នូ-២០១១ | ៤២អនក្រ.បក-១៦ -មីនា-២០១២ |
| ៤៦ | សេ ហុង ផ្លេនថេសិន លីមីធីត | ៩៧០០ | គូលែន( ឧត្តរមានជ័យ-ព្រះវិហារ) | ៨៥អនក្រ.បក-១១-មេសា-២០១២ | ៨៧អនក្រ.បក-០៧-មិថុនា- ២០១២ |
| ៤៧ | ឈុន លីម គ្រុប | ៣០០០ | បន្ទាយឆ្មារ (បន្ទាយមានជ័យ) | ២៥៧អនក្រ.បក-០៨-វិច្ឆិកា-២០១១ | ២៨២អនក្រ.បក-១៣-ធ្នូ-២០១១ |
| ៤៨ | វៀតមីវៀតណាមេន ខូអិលធីឌី | ៧២៨ | ភ្នំក្រោល (មណ្ឌលគិរី) | ៦១អនក្រ.បក-០១-មេសា-២០១១ | ៩៣អនក្រ.បក-២៤-ឧសភា-២០១១ |
| ៤៩ | K-Peace Investment Cambodia Co., Ltd | ៥០០ | ណាមលៀរ (មណ្ឌលគិរី) | ១៣អនក្រ.បក-២០-មករា-២០១១ | ២៨អនក្រ.បក-២១-កុម្ភៈ-២០១២ |
| ៥០ | ទេពី អគ្រូ រីសោស | ១០០០ | បឹងកែរ(កំពង់ធំ) | ១៧៧អនក្រ.បក-០២-សីហា-២០១១ | ២២៨អនក្រ.បក-០៥-តុលា-២០១១ |
| ៥១ | វ៉ឺ ស៊ុនខន អ៊ិនវេសមេនសិន | ៩០០០ | លំផាត់(រតនៈគីរី) | ៨០អនក្រ.បក-០៧-មិថុនា-២០១២ | ១៣៣អនក្រ.បក-២៤-សីហា -២០១២ |
| ៥២ | លីម រ៉ូប៉ាស ជ័យ ស្លុក | ៩០៦៨ | ភ្នំក្រោល(មណ្ឌលគិរី) | ៧៩អនក្រ.បក -០៧-មិថុនា-២០១២ | ២៤៩អនក្រ.បក-១២-ធ្នូ-២០១២ |
| ៥៣ | ជី ឈួង សំណង់&អភិវឌ្ឍន៍ នីហារីណ ផ្លេន្ទ(Green Rubber Development Plantation) | ៦០០០ | គូលែន (សៀមរាប-ព្រះវិហារ) | ៦៣អនក្រ.បក -២៣-មេសា-២០១២ | ១៦១ អនក្រ.បក-២២-កក្កដា-២០១១ |
| ៥៤ | MEGA FIRST CORPORATION BERHAD | ៩៤៧៧ | ណាមលៀរ (មណ្ឌលគិរី) | ៦១ អនក្រ.បក -១៥-មេសា-២០១២ | ៨៨អនក្រ.បក -០៧-មិថុនា- ២០១២ |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩០ សសរ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល
លេខ ៣៧៥៤
ថ្ងៃទី ២៧-១១-១៩, ១១៣
បញ្ជូន

# សេចក្ដីសម្រេច
## ស្ដីពី
## ការតែងតាំងសមាសភាពនៃលេខាធិការដ្ឋានបច្ចេកទេស សម្រាប់សម្បទានដីសេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការកែសម្រួលអនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១** : ត្រូវបានបង្កើតលេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១-ឯកឧត្ដម | **ចាន់ សុខុឡា** | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២-ឯកឧត្ដម | **ម៉េង សុធី** | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |

៣-ឯកឧត្តម **ស្រ៊ុន ដារិទ្ធិ** តំណាងក្រសួងបរិស្ថាន សមាជិក

៤-ឯកឧត្តម **នុត អ៊ុនវ័ណរ៉ា** តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៥-លោក **ម៉ុន ម៉ុណ្ណារិទ្ធ** តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៦-លោក **ចាយ សេខថង** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៧-លោក **សៅ វ៉ារី** តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ សមាជិក

៨-លោក **សាន ចំរើន** តំណាងក្រសួងមហាផ្ទៃ សមាជិក

៩-លោក **ណុំ ស៊ីនិត** តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

**ប្រការ២** : លេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ចនេះ ត្រូវបំពេញភារកិច្ចដូចមានចែងក្នុងអនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច។

**ប្រការ៣** : សេចក្តីសម្រេចលេខ៥៩ សសរ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាព នៃលេខាធិការដ្ឋានបច្ចេកទេស សម្រាប់សម្បទានដីសេដ្ឋកិច្ច និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៤ រោច ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ៤*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្ដីការគណៈរដ្ឋមន្ត្រី**
**លេខៈ ១១៣០ សជណ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
លេខ ...
ថ្ងៃទី ០៣.១០.១២
ហត្ថលេខា...

ទទួលថ្ងៃទី 22/10/12
លេខ 2727

*រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១២*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**គោរពជូន**
**-ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**-ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
√**-ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖ ករណីកែសំរួលការកំណត់ថ្លៃសម្បទានដី និងបង់ប្រាក់កក់ ចំពោះសម្បទានដីសេដ្ឋកិច្ចទាំងអស់ (ទាំងចាស់ ទាំងថ្មី) ។

**យោង** ៖ -លិខិតលេខ ៦៦០ សជណ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១២ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
-ស្មារតីកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១២ ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រី សូមជំរាបជូន ឯកឧត្តម មេត្តាជ្រាបថា ចំពោះករណីនេះ គណៈរដ្ឋមន្ត្រីបានសំរេចធ្វើការកែសំរួលខ្លឹមសារលិខិតលេខ ៦៦០ សជណ ចុះថ្ងៃទី២២ ខែ មិថុនា ឆ្នាំ ២០១២ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ត្រង់ទី ២ ដូចខាងក្រោម ៖

- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ត្រូវបង់ថ្លៃឈ្នួលសម្បទានដីប្រចាំឆ្នាំ គិតចាប់ពីឆ្នាំទី ៦ ទៅ ក្នុងតំលៃចំនួន ៥ ដុល្លារអាមេរិក ក្នុងមួយហិកតា និងកែសំរួលការតំឡើងថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ច ពី ៥% ក្នុងមួយឆ្នាំ មកនៅត្រឹម ១% ក្នុងមួយឆ្នាំវិញ គិតចាប់ពីឆ្នាំទី ៧ តទៅ ដោយមិនធ្វើការបែងចែកទៅតាមប្រភេទដំណាំនោះទេ គឺសំដៅដល់សម្បទានដីសេដ្ឋកិច្ច ដែលធ្វើអាជីវកម្មដាំដុះដំណាំកសិកម្មគ្រប់ប្រភេទ ។

សេចក្ដីដូចបានជំរាបជូនខាងលើ សូមឯកឧត្តម មេត្តាជ្រាប និងចាត់ចែងអនុវត្តន៍តាមការគួរ ។

**ឧ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**អគ្គលេខាធិការ**

**ប្រាក់ សុខុន**

**ចំលងជូន ៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- រដ្ឋបាលព្រៃឈើ
- ក្រុមហ៊ុនវិនិយោគដីសម្បទានសេដ្ឋកិច្ច
- ឯកសារ-កាលប្បវត្តិ

5

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**លេខ** :៩១១ សជណ.ឋក

ថ្ងៃ ៣រ ១០កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**កម្មវត្ថុ៖** ករណីសំណើសុំគោលការណ៍លើការផ្ទេរធនធានចំណូលមិនមែនសារពើពន្ធពីចំណូលថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ។

**យោង៖**
- លិខិតលេខ១៨៤១ សហវ.អទច ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លិខិតលេខ៤៨៤៦ សហវ.អទច ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យជ្រាបថា រាជរដ្ឋាភិបាលឯកភាពលើគោលការណ៍គណនាថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ចឡើងវិញ ដោយកំណត់ថ្លៃឈ្នួលតាមទំហំផ្ទៃដីដែលរដ្ឋបានផ្ដល់ជូន (បច្ចុប្បន្នគណនាតាមផ្ទៃដីអនុញ្ញាតឈូសឆាយ)។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមអគ្គបណ្ឌិតសភាចារ្យជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

**ចម្លងជូន៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងបរិស្ថាន
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ: ១២៧៣ សហវ-ប្រក                    រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩

# ប្រកាស

## ស្តីពីការកំណត់ថ្លៃសួយសារឈើឈរឡើងវិញ ដើម្បីបង់ចំណូលថវិការដ្ឋ

*********

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
### និង
### រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស / រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុក្រឹត្យទាំងឡាយដែលតម្លើង បំពេញបន្ថែម និងកែសម្រួលនាយកដ្ឋាន

មួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ លើលិខិតលេខ ៧៣៥៤ សហវ ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញការចាំបាច់

## ស ម្រេ ច

**ប្រការ ១:**

ថ្លៃសួយសារឈើឈរត្រូវបានកំណត់ សម្រាប់ជាមូលដ្ឋានដាក់ឱ្យដេញថ្លៃ ឬពិគ្រោះថ្លៃ ដូចខាងក្រោម÷

**១- ឈើប្រភេទប្រណិត**

-កូនឈើដែលមានអង្កត់ផ្ចិតទំហំគល់តូចជាង ១៥ សម ស្មើ ១០.០០០ រៀល/ដើម

-ឈើមូលដែលមានអង្កត់ផ្ចិតទំហំគល់ពី ១៥ ទៅ៣០ សម ស្មើ ១១០ ដុល្លារ/ម$^{៣}$

ក-ប្រភេទក្រញូង ស្មើ ២២០ ដុល្លារ/ម$^{៣}$

ខ-ប្រភេទនាងនួន ស្មើ ១៦៥ ដុល្លារ/ ម$^{៣}$

គ-ប្រភេទបេង ស្មើ ១៣៧,៥០ ដុល្លារ/ ម$^{៣}$

-ឈើមូលដែលមានអង្កត់ផ្ចិតទំហំគល់ធំជាង ៣០សម ស្មើ ១៩២,៥០ ដុល្លារ/ម$^{៣}$

ក-ប្រភេទក្រញូង ស្មើ ២៧៥ ដុល្លារ/ ម$^{៣}$

ខ-ប្រភេទនាងនួន ស្មើ ២៤៧,៥០ ដុល្លារ/ម$^{៣}$

គ-ប្រភេទបេង ស្មើ ២២០ ដុល្លារ/ ម$^{៣}$

**២- ឈើប្រភេទលេខ១**

-កូនឈើដែលមានអង្កត់ផ្ចិតទំហំគល់ពី ១៥ ទៅ ៣០សម ស្មើ ២០.០០០រៀល /ដើម

-ឈើមូលដែលមានអង្កត់ផ្ចិតទំហំគល់ធំជាង ៣០ សម ស្មើ ៨២,៥០ ដុល្លារ/ម$^{៣}$

**៣- ឈើប្រភេទលេខ២**

-កូនឈើដែលមានអង្កត់ផ្ចិតទំហំគល់ពី ១៥ ទៅ ៣០សម ស្មើ ១៧.០០០ រៀល /ដើម

-ឈើមូលដែលមានអង្កត់ផ្ចិតទំហំគល់ធំជាង ៣០ សម ស្មើ ៥៥ ដុល្លារ/ម$^{៣}$

**៤- ឈើប្រភេទលេខ៣ និង ក្រៅលំដាប់ថ្នាក់**

-កូនឈើដែលមានអង្កត់ផ្ចិតទំហំគល់ពី ១៥ ទៅ ៣០សម ស្មើ ១៥.០០០ រៀល /ដើម

-ឈើមូលដែលមានអង្កត់ផ្ចិតទំហំគល់ធំជាង ៣០ សម ស្មើ ២៧,៥០ ដុល្លារ/ម$^{៣}$

**៥- កូនឈើចំរុះ**

កូនឈើចំរុះ(លើកលែងប្រភេទឈើប្រណិត) ដែលមានអង្កត់ផ្ចិតទំហំគល់តូចជាង ១៥ សម ស្មើ ២.០០០ រៀល/ដើម

**៦- អុសចំរុះ**

អុសចំរុះ (ប្រើប្រាស់សំរាប់ជាឈើថាមពល និងធ្យូង) ស្មើ ៥.០០០ រៀល/ស្ទែរ



ម

ប្រការ ២:

ចំពោះសម្បទានដីសេដ្ឋកិច្ចត្រូវធ្វើការវាយតម្លៃប៉ាន់ស្មានធនធានផល អនុផលព្រៃឈើតាមអនុតំបន់ដែលអនុញ្ញាតឱ្យឈូសឆាយជាមុន និងត្រូវបង់ថ្លៃសួយសារ និងបុព្វលាភជាបីជំហាន ទើបអនុញ្ញាតឱ្យឈូសឆាយសំអាតដីជាផ្ទុះបាន ។

ប្រការ ៣:

ក្នុងករណីចាំបាច់ ថ្លៃសួយសារនឹងត្រូវបានកំណត់ថ្លៃឡើងវិញជារៀងរាល់ឆ្នាំ នៅខែ ឧសភា រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្ទាប់ពីមានការឯកភាពពីប្រមុខរាជរដ្ឋាភិបាល ។

ប្រការ ៤:

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលព្រៃឈើ ត្រូវចុះពិនិត្យវាយតម្លៃឈើនៅគំនរឈើ ដែលបានកាប់រួច ឬប្រមូលទុក ដើម្បីលក់បង់ចំណូលចូលថវិការដ្ឋ ។

ប្រការ៥ :

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៦ :

អគ្គលេខាធិការ អគ្គនាយក នាយខុទ្ទកាល័យ ប្រធានអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ចាន់-សារុន

កន្លែងទទួល:

- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យរបស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- ដូចប្រការ ៦
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
លេខ : ៣៧១៥ / ៥៥៥ ប្រក-សហវ-កសក

# ប្រកាសរួម

## ស្តីពីការកែសម្រួលប្រការ ២ នៃប្រកាស
## លេខ ១២៧៦ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៩
## ស្តីពីការកំណត់ថ្លៃសួយសារឈើឈរឡើងវិញ ដើម្បីបង់ចំណូលថវិការដ្ឋ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុក្រឹត្យទាំងឡាយដែលដំឡើង បំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអនុក្រឹត្យទាំងឡាយដែលដំឡើង បំពេញបន្ថែម និងកែសម្រួល នាយកដ្ឋានមួយចំនួន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញប្រកាសលេខ ១២៧៦ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ថ្លៃសួយសារឈើឈរឡើងវិញ ដើម្បីបង់ចំណូលថវិការដ្ឋ
-បានឃើញការចាំបាច់

## ស ម្រេ ច

**ប្រការ១ :** ត្រូវបានកែសម្រួលប្រការ ២ នៃប្រកាសលេខ ១២៧៦ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការកំណត់ថ្លៃសួយសារឈើឈរឡើងវិញ ដើម្បីបង់ចំណូលថវិការដ្ឋ ដូចខាងក្រោម :

**ប្រការ២ថ្មី:** ចំពោះសម្បទានដីសេដ្ឋកិច្ចត្រូវធ្វើការវាយតម្លៃប៉ាន់ស្មានធនធានផល អនុផលព្រៃឈើតាមអនុតំបន់ដែលអនុញ្ញាតឱ្យឈូសឆាយជាមុន និងអនុវត្តតាមនីតិវិធីដូចខាងក្រោម :

-ក្រុមហ៊ុនត្រូវដាក់ពាក្យសុំធ្វើការឈូសឆាយតាមអនុតំបន់ដែលបានកំណត់ក្នុងផែនការមេ មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឱ្យបានយ៉ាងតិចបំផុតក្នុងរយៈពេល ០៤ ខែ មុនកាលកំណត់ចាប់ផ្តើមឈូសឆាយ

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងពិនិត្យផ្តល់គោលការណ៍អនុញ្ញាតឱ្យឈូសឆាយក្នុងរយៈពេលមិនលើសពីមួយខែ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំរបស់ក្រុមហ៊ុន

-រដ្ឋបាលព្រៃឈើនឹងសហការជាមួយក្រុមហ៊ុនធ្វើការវាយតម្លៃធនធានផល អនុផលព្រៃឈើ ដែលមានក្នុងអនុតំបន់ដែលទទួលគោលការណ៍សម្រេចអនុញ្ញាតឱ្យឈូសឆាយឱ្យចប់ក្នុងរយៈពេល ០៣ ខែ គិតចាប់ពីថ្ងៃទទួលបានការសម្រេចជាគោលការណ៍ឱ្យឈូសឆាយ

-ចំពោះឈើដែលបានមកពីការឈូសឆាយ ក្រុមហ៊ុនត្រូវរូតរះប្រមូល និងរៀបចំដាក់ជាគំនរ ដើម្បីសហការជាមួយរដ្ឋបាលព្រៃឈើចុះធ្វើការវាស់វែង និងត្រូវបង់ថ្លៃសួយសារ និងបុព្វលាភជូនរដ្ឋតាមនីតិវិធីមុននឹងយកទៅប្រើប្រាស់ ។

សម្រាប់អនុតំបន់ដែលបានទទួលគោលការណ៍អនុញ្ញាតពី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យឈូសឆាយមុនប្រកាសនេះចូលជាធរមាន អាចបន្តអនុវត្តទៅតាមគោលការណ៍ដែលបានសម្រេចរួចហើយនោះ ។

**ប្រការ២ :** អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធានអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ច័ន្ទ.សារុន

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាល
-គ្រប់ក្រសួង ស្ថាប័នកណ្តាល
-ដូចប្រការ២
-គ្រប់សាលាខេត្ត-រាជធានី
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣៦៩ ប្រក. កសក

## ប្រកាស
## ស្តីពី
## ការបង្កើតក្រុមជំនួយការលេខាធិការដ្ឋានបច្ចេកទេសសម្បទានដីសេដ្ឋកិច្ច

---

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសេចក្តីសម្រេចលេខ៥៩ សសរ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការតែងតាំងសមាសភាពនៃលេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច
- យោងតាមសំណើរបស់ឯកឧត្តមប្រធានលេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមជំនួយការលេខាធិការដ្ឋានបច្ចេកទេសសម្បទានដីសេដ្ឋកិច្ច ដែលមានសមាសភាពដូចខាងក្រោម៖

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣)៧២៦ ១២៨ /៧២៦ ១២៩ ទូរសារលេខ: (៨៥៥)២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

| | | | |
|---|---|---|---|
| ១-លោក | ចាន់ ហេង | អគ្គលេខាធិការរង នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២-លោក | សៀ វ៉ា | អនុប្រធានរដ្ឋបាលរដ្ឋបាលព្រៃឈើ | អនុប្រធាន |
| ៣-លោក | គង់ ភាជ | ប្រធាននាយកដ្ឋានកសិ ឧស្សាហកម្ម | អនុប្រធាន |
| ៤-លោក | ម៉ក់ ម៉ូនី | អនុប្រធាននាយកដ្ឋានផែនការនិងស្ថិតិ | អនុប្រធាន |
| ៥-លោក | អៀន ពិសិទ្ធ | អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ៦-លោក | យុន កក្កដា | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ដំណាំកៅស៊ូនៃអគ្គនាយកដ្ឋានកៅស៊ូ | សមាជិក |
| ៧-លោក | ចែ សារុន | អនុប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ | សមាជិក |
| ៨-លោក | អ៊ុំ កន្និដ្ឋា | អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ៩-លោក | អ៊ីន សុភា | អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ១០-លោក | លី ម៉េងសៀង | អនុប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ នៃរដ្ឋបាលព្រៃឈើ | សមាជិក |
| ១១-លោក | ជី សុចិន្តា | ប្រធានការិយាល័យផែនការនៃនាយកដ្ឋានផែនការនិងស្ថិតិ(ន.ផស) | សមាជិក |
| ១២-លោក | ហង់ជួន ចំរ៉ុង | ប្រធានការិ.សម្របសម្រួលតាមដាននិងវាយតម្លៃគម្រោង(ន.ផស) | សមាជិក |
| ១៣-លោក | ទឹម ធុន | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ១៤-លោក | ទូច ប៊ុនធៀង | ប្រធានការិ.គណនេយ្យ នៃនាយកដ្ឋានកសិ ឧស្សាហកម្ម | សមាជិក |
| ១៥-លោក | សុខ ប៉ុណ្ណៈកុសល | អនុប្រធានការិយាល័យរដ្ឋបាលនៃនាយកដ្ឋានកិច្ចការរដ្ឋបាល | សមាជិក |
| ១៦-លោក | ម៉ក់ វិសាល | អនុប្រធានការិ.សម្របសម្រួលតាមដាននិងវាយតម្លៃគម្រោង(ន.ផស) | សមាជិក |
| ១៧-លោក | វន វណ្ណារត្ន | អនុប្រធានការិ.សម្របសម្រួលតាមដាននិងវាយតម្លៃគម្រោង(ន.ផស) | សមាជិក |
| ១៨-លោក | រុន វិសិទ្ធិ | អនុប្រធានការិ.នៃនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស | សមាជិក |
| ១៩-លោក | ហែម សារាវុធ | អនុប្រធានការិយាល័យ នៃរដ្ឋបាលព្រៃឈើ | សមាជិក |
| ២០-លោក | ឈុប ថាវិត | មន្ត្រីនាយកដ្ឋានផែនការនិងស្ថិតិ | សមាជិក |
| ២១-លោក | ថោ សុមាលិន | មន្ត្រីនាយកដ្ឋានផែនការនិងស្ថិតិ | សមាជិក |
| ២២-លោក | ប៊ុត មរកត | មន្ត្រីនាយកដ្ឋានផែនការនិងស្ថិតិ | សមាជិក |
| ២៣-លោក | សូ សីហាសម្បត្តិ | មន្ត្រីនាយកដ្ឋានផែនការនិងស្ថិតិ | សមាជិក |

**ប្រការ២._**

ក្រុមជំនួយការនេះមានភារកិច្ចជួយដល់ប្រធានលេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ចលើការងារៈ

- ចាត់ចែងកិច្ចការរដ្ឋបាលទូទៅ របស់លេខាធិការដ្ឋានបច្ចេកទេស
- ចងក្រង គ្រប់គ្រងទិន្នន័យ ឯកសារ និងផ្សព្វផ្សាយព័ត៌មានដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ច
- រៀបចំ កែប្រែ និងអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគម្រោងសម្បទានដីសេដ្ឋកិច្ច
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃគម្រោងសម្បទានដីសេដ្ឋកិច្ច
- ទទួលការងារផ្សេងៗទៀតដែលប្រធានលេខាធិការដ្ឋានបច្ចេកទេសប្រគល់ជូន។

**ប្រការ៣._**

ប្រកាសលេខ២៧៧ ប្រក.កសក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

Scanned with CamScanner

**ប្រការ៤.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានលេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គ-នាយកដ្ឋានកៅស៊ូ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកសិ-ឧស្សាហកម្ម ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល និងសាមីខ្លួន ដូចក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- សាលាខេត្តពាក់ព័ន្ធ
  «ដើម្បីជូនជ្រាប»
- ដូចប្រការ៤
  «ដើម្បីអនុវត្ត»
- ឯកសារ កាលប្បវត្តិ

Scanned with CamScanner

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៦២១ ប្រក.កសក

## ប្រកាស
### ស្តីពី
### ការកែសម្រួលប្រធានក្រុមជំនួយការលេខាធិការដ្ឋានបច្ចេកទេស សម្រាប់សម្បទានដីសេដ្ឋកិច្ច

### រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/២០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសេចក្តីសម្រេចលេខ៥៩ សសរ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការតែងតាំងសមាសភាពនៃលេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច
- បានឃើញប្រកាសលេខ៣៦៩ ប្រក.កសក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការបង្កើតក្រុមជំនួយការលេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

Scanned with CamScanner

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

## សម្រេច

**ប្រការ១._**

ត្រូវបានកែសម្រួលប្រធានក្រុមជំនួយការលេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច ពីលោក **ចាន់ ហេង** អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មកលោក **ម៉ាន ណារ៉ា** អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិញ។

**ប្រការ២._**

ក្រៅពីការកែសម្រួលប្រធានក្រុមជំនួយការក្នុងប្រការ១ ខ្លឹមសារទាំងឡាយនៃសេចក្ដីសម្រេចលេខ៣៦៩ ប្រក.កសក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានរក្សាទុកដដែល។

**ប្រការ៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤._**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានលេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានកសិ-ឧស្សាហកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល និងសាមីខ្លួនដូចក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- សាលាខេត្តពាក់ព័ន្ធ
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ

Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក ស ក**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៤៩៦៧ កសក

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៣

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**<u>ជម្រាបមក</u>**

**ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី**

**នាយកក្រុមហ៊ុន**..........................................................

**<u>កម្មវត្ថុ៖</u>** សេចក្តីណែនាំលើការអនុវត្តនិងការផ្តល់របាយការណ៍ស្តីពី លទ្ធផលនៃការអនុវត្តគម្រោងវិនិយោគដីសម្បទានសេដ្ឋកិច្ច។

**<u>ជូនភ្ជាប់៖</u>**-ទម្រង់របាយការណ៍ ស្តីពីលទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចប្រចាំត្រីមាស

-ទម្រង់របាយការណ៍ ស្តីពីលទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចប្រចាំឆមាសនិងប្រចាំឆ្នាំ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី នាយកក្រុមហ៊ុនជ្រាបថា៖ កន្លងមកតាមការកត់សម្គាល់របស់ក្រសួងឃើញថាបណ្តាក្រុមហ៊ុនវិនិយោគមួយចំនួន ដំណើរការអនុវត្តគម្រោងវិនិយោគរបស់ខ្លួនបានល្អនិងក្រុមហ៊ុនមួយចំនួនទៀតអនុវត្តមិនបានល្អមានការយឺតយ៉ាវបើប្រៀបធៀបទៅនឹងកិច្ចសន្យានិងផែនការមេ និងខ្លះទុកដីចោលទំនេរដោយគ្មានការអភិវឌ្ឍន៍ និងគ្មានការទទួលខុសត្រូវ បណ្តោតបណ្តោយឲ្យមានបទល្មើសរំលោភបំពានក្នុងដីសម្បទានទាំងនោះ។ ទន្ទឹមនេះបណ្តាក្រុមហ៊ុនវិនិយោគមួយចំនួនពុំបានផ្តល់របាយការណ៍ស្តីពីសកម្មភាពវិនិយោគរបស់ក្រុមហ៊ុន ជូនមកក្រសួងឲ្យបានទៀងទាត់ តាមពេលវេលាកំណត់នៅឡើយ។ ដូច្នេះដើម្បីជំរុញការអនុវត្តគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចឲ្យដំណើរការទៅបានល្អ និងដើម្បីក្រសួងមានមូលដ្ឋានគ្រប់គ្រងតាមដានត្រួតពិនិត្យវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តរបស់ក្រុមហ៊ុន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមស្នើឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី នាយកក្រុមហ៊ុន ផ្ញើរបាយការណ៍ជាប្រចាំពីលទ្ធផលសម្រេចបានរបស់ក្រុមហ៊ុនជូនមកក្រសួងជាទម្រង់របាយការណ៍ត្រីមាស ឆមាស និងប្រចាំឆ្នាំ តាមទម្រង់របាយការណ៍ជូនភ្ជាប់ឲ្យបានទៀងទាត់។ ចំពោះពេលវេលានៃការផ្តល់របាយការណ៍នីមួយៗជូនក្រសួងត្រូវធ្វើឡើងឲ្យបានទៀងទាត់រៀងរាល់ចុងសប្តាហ៍ទី៣នៃខែដំណាច់ត្រីមាស ឆមាស និងឆ្នាំ ដោយគិតចាប់ពីខែកញ្ញា ឆ្នាំ២០១៣នេះតទៅ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី នាយកក្រុមហ៊ុនជ្រាប និងចាត់វិធានការអនុវត្តឲ្យមានប្រសិទ្ធភាព។

**ត.ប រដ្ឋមន្ត្រី**

**អគ្គលេខាធិការ**

<u>ចម្លងជូន៖</u>
-លេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច
-រដ្ឋបាលព្រៃឈើ
-អគ្គនាយកដ្ឋានកសិកម្ម
-នាយកដ្ឋានកសិឧស្សាហកម្ម
-មន្ទីរកសិកម្មរាជធានី-ខេត្ត..............
-ឯកសារ កាលប្បវត្តិ

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៦៩៧ ស.ណ.ន.កសក

# សេចក្តីណែនាំ

## ស្តីពី

## វិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច

កន្លងមកនេះ គម្រោងសម្បទានដីសេដ្ឋកិច្ចត្រូវបានរាជរដ្ឋាភិបាលសម្រេចឲ្យស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត។ ដោយអនុលោមតាមស្មារតីនៃអនុក្រឹត្យលេខ១៣១ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច និងអនុក្រឹត្យលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ស្តីពីការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាននោះ គម្រោងសម្បទានដីសេដ្ឋកិច្ចទាំងអស់ ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទវិញ។ បច្ចុប្បន្ននេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកត់សម្គាល់ឃើញថា ការអនុវត្តគម្រោងសម្បទានដីសេដ្ឋកិច្ចនៅមានចំណុចខ្វះខាត និងបញ្ហាប្រឈមជាច្រើនដូចជាទីតាំងសម្បទានដីសេដ្ឋកិច្ចមួយចំនួននៅមិនទាន់បានចុះបញ្ជីដីរដ្ឋ ធ្វើអនុបយោគពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ និងដោះស្រាយផលប៉ះពាល់ជាមួយប្រជាពលរដ្ឋនៅឡើយ ដែលជាហេតុបណ្តាលឲ្យមានការយឺតយ៉ាវដល់ការអភិវឌ្ឍលើគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចប្រកបដោយជោគជ័យ និងមិនអាចអនុវត្តឲ្យបានត្រឹមត្រូវស្របតាមគោលការណ៍ដូចបានចែងក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន និងកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចឡើយ។ ហេតុនេះ ដើម្បីឲ្យការអនុវត្តគម្រោងសម្បទានដីសេដ្ឋកិច្ចមានដំណើរការអភិវឌ្ឍន៍ទៅមុខទទួលបានជោគជ័យប្រកបដោយសុខដុមនីយកម្ម ជៀសវាងធ្វើឲ្យប៉ះពាល់ដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល និងជាពិសេស ដើម្បីជំរុញប្រសិទ្ធភាពនៃការអនុវត្តអនុក្រឹត្យលេខ១៤៦ អនក្រ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច បទបញ្ជាលេខ០១បប ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ព្រមទាំងសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីពាក់ព័ន្ធវិធានការបន្តលើបញ្ហាសម្បទានដីសេដ្ឋកិច្ច និងផ្អែកលើតម្រូវការចាំបាច់ និងបន្ទាន់ចំពោះមុខ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំអំពីវិធានការអនុវត្តបន្ថែមដល់អង្គភាពជំនាញពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ អាជ្ញាធរដែនដី និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ដូចខាងក្រោម៖

១. ត្រូវជំរុញគ្រប់វិធានការក្នុងការអនុវត្តរាល់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ក៏ដូចជារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងបំពេញបន្ថែមនូវចំណុចខ្វះខាតកន្លងមកឲ្យបានសមស្របតាមនីតិវិធីដល់បណ្តាក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទាំងអស់ ដើម្បីឈានដល់ការចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគមកនៅត្រឹម៥០ឆ្នាំ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងម្ចាស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច។

២. មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលតំណាងឲ្យអាជ្ញាធរកាន់កាប់ដីរដ្ឋ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ត្រូវជំរុញការចុះបញ្ជីដី ដោយសហការជាមួយម្ចាស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ក្នុងការចុះ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣)៧២៦ ១២៨ /៧២៦ ១២៩ ទូរសារលេខ: (៨៥៥)២៣-២១៧ ៣២០
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

Scanned with CamScanner

អនុវត្តឲ្យបានទាន់ពេលវេលា។ ក្នុងករណីបោះបង្គោលព្រំតំបន់សម្បទានដីសេដ្ឋកិច្ច មានផ្ទុះបាតុភាពតវ៉ាពីប្រជាពលរដ្ឋ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងម្ចាស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ត្រូវរាយការណ៍ជូនឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្ត ដើម្បីដោះស្រាយជាបន្ទាន់ក្នុងនាមប្រធានគណៈកម្មការដោះស្រាយទំនាស់ដីរដ្ឋថ្នាក់ខេត្ត។

៣.ជួយជំរុញ និងសហការឲ្យបានជិតស្និទ្ធ ព្រមទាំងជួយពន្យល់ណែនាំដល់ប្រជាពលរដ្ឋគ្រប់រូបឲ្យបានយល់ច្បាស់អំពីផលប្រយោជន៍នៃគោលការណ៍អនុវត្តសម្បទានដីសេដ្ឋកិច្ច ដើម្បីជៀសវាងផលប៉ះពាល់ផ្សេងៗជាអវិជ្ជមានដែលអាចកើតឡើងជាយថាហេតុ។

៤. ត្រូវជំរុញឲ្យបណ្ដាក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចនីមួយៗបង្កើតឲ្យមានស្នាក់ការ ការិយាល័យបម្រើការងាររបស់ខ្លួននៅតាមទីរួមខេត្ត ដែលក្រុមហ៊ុនកំពុងប្រតិបត្តិការ ដើម្បីងាយស្រួល ក្នុងការទំនាក់ទំនង ឬសុំកិច្ចអន្តរាគមន៍ណាមួយតាមការចាំបាច់ ព្រមទាំងជំរុញឲ្យម្ចាស់ក្រុមហ៊ុនផ្ដល់នូវរបាយការណ៍វឌ្ឍនភាពឲ្យបានទៀងទាត់តាមពេលវេលាដែលបានកំណត់ ដោយមានទិន្នន័យជាក់លាក់ ត្រូវចុះហត្ថលេខា និងឈ្មោះរបស់ប្រធានក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងត្រូវប្រថាប់ត្រាឲ្យបានសមស្របតាមនីតិវិធីរដ្ឋបាល។

៥. មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវណែនាំដល់មន្ត្រីជំនាញរដ្ឋបាលព្រៃឈើពិនិត្យឲ្យបានម៉ត់ចត់ក្នុងការចេញលិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើ ដែលមានប្រភពចេញពីសម្បទានដីសេដ្ឋកិច្ចដោយត្រូវចាត់មន្ត្រីជំនាញរដ្ឋបាលព្រៃឈើធ្វើការតាមដាន និងត្រួតពិនិត្យមើលឈើខុសច្បាប់ដែលជ្រកក្រោមរោងអារឈើ សិប្បកម្មកែច្នៃឈើ រោងសន្និធិផល អនុផលព្រៃឈើ ពិសេសបន្ទាប់ពីទទួលបានលិខិតអនុញ្ញាតឲ្យឈូសឆាយសម្បទានដីសេដ្ឋកិច្ច។

៦. មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានរដ្ឋបាលព្រៃឈើមូលដ្ឋានជាសេនាធិការ ត្រូវចាត់វិធានការគ្រប់គ្រងដីព្រៃឈើ ដែលបានដកហូតពីគម្រោងសម្បទានដីសេដ្ឋកិច្ច និងតាមដីកាដកហូតរបស់គណៈអភិបាលខេត្ត ដោយត្រូវកសាងផែនទីទីតាំងដី និងមានចុះហត្ថលេខាទទួលស្គាល់ពីអាជ្ញាធរដែនដី និងអង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ដើម្បីស្វែងរកដៃគូអភិវឌ្ឍន៍ព្រៃឈើឡើងវិញ។

៧. ត្រូវអនុវត្តឲ្យបានម៉ឺងម៉ាត់នូវសារាចរណែនាំលេខ០៥ សរណន ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្ដីពីវិធានការចាំបាច់ក្នុងការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ។

ទទួលបានសេចក្ដីណែនាំនេះ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ត្រូវសហការជាមួយអាជ្ញាធរដែនដី និងអង្គភាពពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ដើម្បីធ្វើការផ្សព្វផ្សាយ និងអនុវត្តឲ្យមានប្រសិទ្ធភាពក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលនៃការអនុវត្តមកក្រសួងវិញ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

-គ្រប់សាលារាជធានី ខេត្ត

-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនសាទ

-គ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនសាទរាជធានី ខេត្ត

-ឯកសារ កាលប្បវត្តិ

Scanned with CamScanner

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣៥១៤ កសក

រាជធានីភ្នំពេញ, ថ្ងៃទី..២៣..ខែ..សីហា..ឆ្នាំ ២០១៧

**សូមជម្រាបមក**

**ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី នាយកក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច**

**កម្មវត្ថុ** ៖ សំណើរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមឲ្យបានរួចរាល់តាមនីតិវិធី ។

**យោង** ៖-លិខិតលេខ ១១៨៨ សណប.ស្ត របស់ក្រសួងបរិស្ថាន ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧

-ចំណារឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រីនាយកក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ជ្រាបថា បច្ចុប្បន្ននេះ មានក្រុមហ៊ុន វិនិយោគសម្បទានដីសេដ្ឋកិច្ចមួយចំនួនដែលបាន និងកំពុងដំណើរការធ្វើសកម្មភាព លើទីតាំងដីសម្បទានមួយចំនួនពុំបានរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនៅឡើយ។ ដូច្នេះដើម្បីឲ្យកិច្ចដំណើរការគម្រោងវិនិយោគរបស់ក្រុមហ៊ុនស្របតាមខ្លឹមសារនៃកិច្ចសន្យា និងនីតិវិធីច្បាប់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទាំងអស់ ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនៃគម្រោងវិនិយោគរបស់ខ្លួនឲ្យបានចប់សព្វគ្រប់ និងដាក់ជូនក្រសួងបរិស្ថានដើម្បីពិនិត្យ និងសម្រេច។ ដោយឡែកចំពោះក្រុមហ៊ុនដែលមានការសម្រេចពីក្រសួងបរិស្ថាន លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញរួចហើយនោះ សូមផ្តល់ឯកសារសម្រេចនេះជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឲ្យបានឆាប់រហ័ស។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រីនាយកក្រុមហ៊ុនជ្រាប និងអនុវត្តតាមខ្លឹមសារខាងលើឲ្យបានសមស្របតាមការគួរ។

សូម ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រីនាយកក្រុមហ៊ុន មេត្តាទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**អគ្គលេខាធិការ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ញ៉ា រស្មី

**ចម្លងជូន:**

- ក្រសួងបរិស្ថាន
- សាលាខេត្តពាក់ព័ន្ធ
- លេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច
  "ដើម្បីជូនជ្រាប"
- រដ្ឋបាលព្រៃឈើ
- នាយកដ្ឋានផែនការនិងស្ថិតិ
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពាក់ព័ន្ធ
  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ១០៧៧៣ កសក

រាជធានីភ្នំពេញ, ថ្ងៃ ច័ន្ទ ៨ រោច ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១
ថ្ងៃទី ១១ ខែធ្នូ គ.ស ២០១៧

# លិខិតជូនដំណឹង
## ស្តីពី
## ការជំរុញការអនុវត្តកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនរដ្ឋ

គណៈកម្មការអន្តរក្រសួងចុះពិនិត្យ និងប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចបង់ចូលថវិការដ្ឋ សូមជម្រាបជូន លោក លោកស្រី ជាម្ចាស់ក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ចជ្រាបថា រហូតមកដល់ពេលនេះ នៅតែមានក្រុមហ៊ុនមួយចំនួនមិនទាន់បានបំពេញកាតព្វកិច្ចក្នុងការបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនរដ្ឋ ឱ្យបានពេញលេញ និងទាន់ពេលវេលាដូចមានចែងក្នុងកិច្ចសន្យារវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ច និងខ្លឹមសារសេចក្តីជូនដំណឹងលិខិតលេខ៦៦០ សជណ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១២ លិខិតលេខ១១៣០សជណ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២ និងលិខិតលេខ១១៨៥ សជណ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី នៅឡើយទេ។ ដើម្បីអនុវត្តឱ្យខ្ជាប់ខ្ជួននូវខ្លឹមសារខាងលើនេះ គណៈកម្មការអន្តរក្រសួងចុះពិនិត្យ និងប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចបង់ចូលថវិការដ្ឋ សូមស្នើលោក លោកស្រីជាម្ចាស់ក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ចត្រូវរួសរាន់បង់ថ្លៃសម្បទានដីសេដ្ឋកិច្ចតាមឆ្នាំដែលដល់ពេលត្រូវបង់ឱ្យបានមុនថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨ នេះកុំបីខាន។

គណៈកម្មការអន្តរក្រសួងចុះពិនិត្យ និងប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចបង់ចូលថវិការដ្ឋ សង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រីជាម្ចាស់ក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ចទាំងអស់ មានឆន្ទៈទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនរដ្ឋ ឱ្យបានទាន់ពេលវេលាកំណត់។

**អនុរដ្ឋលេខាធិការ**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធាន**
**គណៈកម្មការអន្តរក្រសួងចុះពិនិត្យ និងប្រមូលចំណូល**
**ថ្លៃសម្បទានដីសេដ្ឋកិច្ចបង់ចូលថវិការដ្ឋ**

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- លេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច
  "ដើម្បីជូនជ្រាប"
- នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ
- នាយកដ្ឋានផែនការ និងស្ថិតិ
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តពាក់ព័ន្ធ
- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចពាក់ព័ន្ធ
  "ដើម្បីជ្រាប និងសហការ"
- ឯកសារ កាលប្បវត្តិ

Scanned with CamScanner

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក ស ក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ២០០២ កសក

ថ្ងៃ.ព្រហស្បតិ៍..៤.រោច.ខែ.មាឃ....ឆ្នាំ..ច..សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី...២៤.....ខែ..មករា.....ឆ្នាំ២០១៩

**ជម្រាបមក**

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រីអគ្គនាយក អគ្គនាយិកា នាយក នាយិកា ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច**

**កម្មវត្ថុ ៖** ស្តីពីការពង្រឹងការអនុវត្តគម្រោងសម្បទានដីសេដ្ឋកិច្ច។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាប ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ជ្រាបថា កន្លងមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានធ្វើការណែនាំដល់បណ្តាក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ចទាំងអស់ឱ្យធ្វើការសហការជាមួយរដ្ឋបាលខេត្ត និងស្ថាប័នពាក់ព័ន្ធក្នុងការជំរុញការដោះស្រាយផលប៉ះពាល់ជាមួយប្រជាពលរដ្ឋ និងអនុវត្តការចុះបញ្ជីដីរដ្ឋ។ ទន្ទឹមនឹងនេះ ដើម្បីមានមូលដ្ឋានក្នុងការផ្តល់គោលការណ៍អនុញ្ញាតជូនក្រុមហ៊ុនធ្វើការឈូសឆាយឱ្យបានទាន់ពេលវេលាស្របតាមផែនការមេ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តម្រូវឱ្យក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចធ្វើការទំនាក់ទំនងដោយផ្ទាល់ទៅរដ្ឋបាលព្រៃឈើស្នើសុំរៀបចំសារពើភ័ណ្ឌផល អនុផលព្រៃឈើចំពោះអនុតំបន់ណាដែលមានសុវត្ថិភាពពេញលេញ។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ជ្រាប និងអនុវត្តតាមខ្លឹមសារខាងលើតាមការគួរ។

សូម ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន៖**
- លេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច
- រដ្ឋបាលខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- អគ្គាធិការដ្ឋាន
- រដ្ឋបាលព្រៃឈើ
- នាយកដ្ឋានផែនការ និងស្ថិតិ
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពាក់ព័ន្ធ
  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

Scanned with CamScanner

អាសយដ្ឋាន៖ លេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
ទូរស័ព្ទលេខ ៖ (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ ៖ (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក ស ក

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ១២០៩១ កសក

ថ្ងៃ សុក្រ ១១ រោច ខែ កត្តិក ឆ្នាំ កុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០១៩

**ជម្រាបមក**

**លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត**

**កម្មវត្ថុ ៖** ស្តីពីការយកចិត្តទុកដាក់ពង្រឹងការចុះបញ្ជីដីរដ្ឋក្នុងដែនសមត្ថកិច្ចរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាប លោកប្រធាន ជ្រាបថា ដើម្បីចូលរួមចំណែកពង្រឹងការងារចុះបញ្ជីដីរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់នោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមធ្វើការណែនាំដូចខាងក្រោម៖

១-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់ជំរុញការចុះបញ្ជីដីរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយត្រូវបំពេញបែបបទតាមនីតិវិធីច្បាប់ជាធរមាន។

២-ក្នុងអំឡុងពេលជូនដំណឹងស្តីពីការបិទផ្សាយជាសាធារណៈនូវលទ្ធផលអង្កេតវាស់វែង និងធ្វើអត្តសញ្ញាណកម្មដី(ឯកសារវិនិច្ឆ័យក្បាលដី)ដើម្បីចុះបញ្ជីដីរដ្ឋ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់ឱ្យបានច្បាស់លាស់ និងត្រឹមត្រូវរាល់ទិន្នន័យក្បាលដី និងបុគ្គលពាក់ព័ន្ធនឹងក្បាលដីដែលស្នើសុំចុះបញ្ជីដីរដ្ឋ រួចរាយការណ៍ជូនក្រសួងបន្ទាន់ ដើម្បីពិនិត្យនិងសម្រេច។

៣-បន្ទាប់ពីការចុះបញ្ជីដីចប់ជាស្ថាពរ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវបញ្ជូនឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីជូនក្រសួងដូចជា៖ (១).ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុច្បាប់ដើម (២).ផែនទីចុះបញ្ជីដីច្បាប់ដើម (៣).កំណត់ហេតុ និងរបាយការណ៍អង្កេតវាស់វែង និងធ្វើអត្តសញ្ញាណកម្មដី (៤).ចំណុចនិយាមកាចុះបញ្ជីដី។

អាស្រ័យហេតុនេះ សូម លោកប្រធាន ជ្រាប និងអនុវត្តតាមខ្លឹមសារខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់តាមការគួរ។

សូម លោកប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន៖**
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
  "ដើម្បីជូនជ្រាប"
- លេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច
- រដ្ឋបាលរាជធានី ខេត្ត
- រដ្ឋបាលជលផល
- រដ្ឋបាលព្រៃឈើ
- អគ្គនាយកដ្ឋានកសិកម្ម
- នាយកដ្ឋានផែនការ និងស្ថិតិ
  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ១៣៣០៤/១៩ កសក.ឥប

ថ្ងៃ...........ខែ...........ឆ្នាំ...........ស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៩

**ជម្រាបជូន**
**លោកនាយក លោកស្រីនាយិកាម្ចាស់ក្រុមហ៊ុនវិនិយោគដីសម្បទានសេដ្ឋកិច្ចគ្រប់បណ្ដាខេត្ត**

**កម្មវត្ថុ** ៖ ស្ដីពីការកំណត់លើការគណនាថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ចត្រូវបង់ចូលថវិការដ្ឋ។
**យោង** ៖ លិខិតលេខ៨១១ សជណ.ហជ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោកនាយក លោកស្រីនាយិកា ជ្រាបថា រាជរដ្ឋាភិបាលបានសម្រេចជាគោលការណ៍គណនាថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ច ដោយកំណត់យកថ្លៃឈ្នួលតាមទំហំផ្ទៃដីដែលរដ្ឋបានផ្ដល់ជូន (បច្ចុប្បន្នគណនាតាមផ្ទៃដីអនុញ្ញាតឈូសឆាយ) តាមរយៈលិខិតលេខ៨១១ សជណ. ហជ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ដែលចាប់ផ្ដើមអនុវត្តចាប់ពីខែមករា ឆ្នាំ២០២០ ខាងមុខនេះតទៅ។

អាស្រ័យហេតុនេះ សូម លោកនាយក លោកស្រីនាយិកា ជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ តាមការគួរ។

សូម លោកនាយក លោកស្រីនាយិកា ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន ៖**
- នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ
- នាយកដ្ឋានកិច្ចការរដ្ឋបាល
  "ដើម្បីមុខការ"
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត
  "ដើម្បីជ្រាប និងសហការផ្សព្វផ្សាយ"
- ឯកសារ កាលប្បវត្តិ

Scanned with CamScanner